ខេមរភាសា

ច. ឈុំ

ចាងហ្វាងសាលារៀនឧបដ្ឋដីឡ្បាគ្រូ

# ពាក្យ

## ភាសា – អក្ខរាវិរុទ្ធរបស់ពាក្យ

# VOCABULAIRE

## LANGAGE-ORTHOGRAPHE

បោះពុម្ពលើកទី ៥

ទុកសិទ្ធិ

TOUS DROITS RÉSERVÉS

ព.ស. ២៥០១ – គ.ស. ១៩៥៨

CA 11

ខេមរភាសា

ច. ឈុំ

អតីតចាងហ្វាងសាលារៀនព្រះអង្គអេង (ឧបដ្ឋវិទ្យាគ្រូ)

# ពាក្យ

## ភាសា–អក្ខរាវិរុទ្ធរបស់ពាក្យ

បោះពុម្ពលើកទី ៤

ការផ្សាយរបស់

បណ្ណាគារ

រស្មីកម្ពុជា

ទុកសិទ្ធិ

TOUS DROITS RÉSERVÉS

ព. ស. ២៥០០ គ. ស. ១៩៥៨

N· 2468

# CONSEIL DES MINISTRES

# PRAKAS

## LE MINISTRE DE L'ÉDUCATION NATIONALE ET DE LA JEUNESSE

Vu la Constitution du Royaume;

Vu le Traité Franco-Khmer en date du 8 Novembre 1949 et ses accords d'application;

Vu le Krâm n· 171-NS du 15 Avril 1946;

Vu le Kret n· 125-NS du 1er Juin 1950;

Vu le Procès-Verbal en date du 4 Août 1950 de la Commission pour Enseignement Primaire Khmer (1re sous-section)

ARRÊTE :

*Article unique.*— Le manuel rédigé en cambodgien par M. CH. CHHUM, Directeur de l'École Doudart de Lagrée, ayant pour titre ពាក្យ ភាសា. អក្ខរាវិរុទ្ធ របស់ពាក្យ», :VOCABULAIRE LANGAGE – ORTHOGRAPHE'', est ajouté à la liste des manuels et publications scolaires dont l'usage est autorisé dans les écoles publiques du Cambodge pour l'année scolaire 1950-1951.

Phnôm-Penh, le 31 Octobre 1950
*Signé :* PITOU DE MONTEIRO.

POUR COPIE CONFORME :
*Pour le Secrétaire Général*
*du Conseil des Ministres et p.o.*
*Le Secrétaire Général-Adjoint*
*Signé:* CHAI-THOUL

POUR AMPLIATION :
*Le chef de Cabinet,*
*Signé:* YEIM-YISINN.

លេខ១-៥៤២៥ ក.

រដ្ឋមន្ត្រីក្រសួងសិក្សាធិការនិងយុវបរិយា

មកលោក អ៊ុំ-ឈុំ ចាងហ្វាងសាលាឧត្ដមវិជ្ជាគ្រូភ្នំពេញ

សូមជ្រាប ។

តបសំបុត្រលោកចុះថ្ងៃទី ២៤ កក្កដា គ.ស.១៩៥០

គណៈកម្មការរងបឋមសិក្សាខ្មែរ បានពិនិត្យមើលសៀវភៅ «ពាក្យ» ពីថ្ងៃ ៤ ខែសីហា គ.ស. ១៩៥០ យល់ព្រមបញ្ចូលសៀវភៅ «ពាក្យ» នេះ ទៅក្នុងពួកសៀវភៅសិក្សាតាមពាក្យលោកសុំ ដើម្បីជាប្រយោជន៍សាធារណៈដល់សាលារៀនទូទៅ ក្នុងព្រះរាជអាណាចក្រ ។

ប៉ុន្តែគណៈកម្មការនេះ សុំឲ្យលោកកែតម្រូវពាក្យខ្លះដែលបោះពុម្ពខុស ហើយនិងពាក្យខ្លះដែលពន្យល់ពុំបានពេញលេញ ដូចមានស្រង់ហើយកែតម្រូវតាមសេចក្ដីកត់ហេតុជាប់មកជាមួយនេះស្រាប់ ។

ខ្ញុំសូមសរសើរចំពោះលោក ដែលមានព្យាយាមតែងនិងរៀបរៀងសៀវភៅ «ពាក្យ» នេះ ឲ្យកើតឡើងដោយមានប្រាថ្នាចង់លើកដំកើងអក្សរសាស្ត្រ និងភាសាជាតិឲ្យបានថ្កុំថ្កើងរុងរឿងតទៅ ។

ភ្នំពេញថ្ងៃទី ២១ សីហា គ.ស. ១៩៥០

ពីទូជីមុងតៀវ

---

ពាក្យខ្លះដែលបោះពុម្ពខុសហើយនិងសេចក្ដីខ្លះដែលពន្យល់ពុំបានពេញលេញកាលបោះពុម្ពលើកដំបូងនោះបានកែសម្រួលត្រឹមត្រូវហើយ តាមបង្គាប់ពីគណៈកម្មការរងបឋមសិក្សាខ្មែរ ។

*Phnom-Penh, 24 Juin 1950*

*Monsieur le Directeur,*

En retour de votre gracieux souvenir : le manuel intitulé «Peak» dont vous avez bien voulu adresser à chacun de nous un éxemplaire, nous vous remercions sincèrement et infiniment.

Nous avons pris connaissance de votre livre avec intérêt et nous croyons qu'il nous sera un guide utile et sûr dans l'enseignement du vocabulaire Khmer.

Nous vous renouvelons nos remerciements, Monsieur le Directeur et nous ne manquerons pas de Communiquer la publication de cet ouvrage à tous nos camarades et élèves dans le but de contribuer à votre éclatant succès.

Veuillez agréer, Monsieur le Directeur, l'assurance de nos sentiments les plus respectueux et dévoués.

*P. le Personnel de l'Ecole Doudart de Lagrée.*

NONG-SONN

*Phnom-Penh, le 30 Juin 1950*

à Monsieur OUM-CHHUM,
*Directeur de l'Ecole Doudart de Lagrée,*
*Auteur du Manuel «PEAK»*

Monsieur,

Ce m'est un très grand plaisir de vous confirmer combien je suis sensible du don d'un livre intitulé «Péak» que vous avez bien voulu me destiner, et je vous en exprime tous mes sincères remerciements.

Étant à la portée de tout le monde, ce manuel rendra de grands services aux maîtres qui peuvent y puiser à volonté ce qu'ils écrivaient et parlaient avec tant de difficultés et hésitations.

Je tiens à vous préciser qu'il est, en notre pays peu d'esprit qui se préoccupe réellement du sort de la littérature. Ainsi, conçu particulièrement en vue de pallier aux erreurs dues à la routine, ce manuel ne présente que d'incontestables avantages, d'autant plus qu'il constitue un guide sûr et précieux pour l'étude du vocabulaire et de l'orthographe Khmers.

Veuillez accepter l'expression de mes meilleurs sentiments.

MORY
*Inspecteur Ajoint*
*Enseignement Kandal,*

*Phnom-Penh, le 24 Octobre 1950*

à Monsieur OUM-CHHUM,

*Directeur de l'Ecole Doudart de Lagrée*

*à PHNOM-PENH*

Monsieur,

En vous accusant réception d'un manuel «PÉAK» dont vous êtes l'auteur,

J'ai l'honneur de vous prier de bien vouloir trouver ici ma très vive reconnaissance.

Cet ouvrage dont l'édition ne saurait que gagner l'agrément des lecteurs, présente, à mon avis, une très haute valeur éducative. Il est rare de trouver un livre de vocabulaire cambodgien qui, d'une part, s'adapte bien à tous les degrés culturels, et d'autre part, instruit les gens tout en les amusant.

Vous contribuerez, dans une large part, par votre constant souci d'être utile à la nation, au progrès tant du monde scolaire que du public studieux, et vous prendrez, à n'en pas douter, une place honorable parmi les auteurs Khmers au sein du cercle littéraire national.

Veuillez recevoir, Monsieur le Directeur, mes chaleureuses félicitations et mes souhaits de bons succès.

DIEP-PHÉAT

*Inspecteur-Adjoint Phnom-Penh.*

**MINISTERE DE L'ÉDUCATION NATIONALE**

**MINISTRE**

*Le 18 Février 1951*

Mon cher Directeur,

J'ai reçu votre livre et vous félicite chaleureusement de l'avoir rédigé. Il vient heureusement combler une lacune. Il sera pour nos collègues ainsi que pour tous ceux qui aiment l'orthographe exacte un guide précieux.

*Bien cordialement*

HUY-KANTHOUL

# អារម្ភកថា

សៀវភៅ « ពាក្យ » នេះ គាប់ឲ្យអ្នករៀនអក្សរនិងភាសាខ្មែរ ស្គាល់ពាក្យពិតប្រាកដ ចេះសរសេរត្រឹមត្រូវតាមអក្ខរៈ មិនសរសេរតាមតែបាន ឬ តាមតែចិត្តឥតមានគោលចារិកនោះឡើយ ។

ពាក្យដែលមានទាំងប៉ុន្មាន គឺខ្ញុំជ្រើសរើសរៀងតាមព្យញ្ជនៈ សំដៅយកតែពាក្យណាដែលត្រូវការប្រើញឹកញយ ហើយមានប្រយោជន៍ជាងគេទៀតផង មកធ្វើជាគោល ព្រមទាំងមានសេចក្ដីអធិប្បាយពន្យល់នូវពាក្យនិមួយៗ អំពីបទវេយ្យាករណ៍ អំពីអក្ខរវិរុទ្ធរបស់ពាក្យ ដែលច្រើននាំឲ្យគាន់ច្រឡំ ហើយនិងរបៀបប្រើពាក្យទាំងនោះបងធ្វើជាឃ្លាចំរុះគ្នា បញ្ចូលពាក្យពិបាកផ្សេងៗ ច្រើនទៅទៀត ដើម្បីឲ្យអ្នកសិក្សាគ្រងគ្រាប់បានដោយងាយ ហើយមានពាក្យទំទឹមទំនៀមបុរាណដាក់ដោយសង្កាត់ទៀតផង ។

ខ្ញុំមានចិត្តសង្ឃឹមទុកជាមុនថា សៀវភៅបែបនេះដែលពុំទាន់មាននៅឡើយ និងពេញចិត្តដល់លោក-អ្នក-នាងជាអ្នកស្នេហាអក្សរនិងភាសាជាតិជាពុំខាន ។

តុលា គ.ស. ១៩៥០

ឈុំ

# អក្សរសង្ខេប

| | | |
|---|---|---|
| កិ. | | កិរិយាសព្ទ |
| កិ. | វិ. | កិរិយាវិសេសន៍ |
| គុ. | | គុណនាម |
| ន. | | នាម |
| និ. | ស. | និបាតសព្ទ |
| ម. | បិ. | មើលថា |
| ម. | សំ. | មគធៈទីធំសំស្រ្កឹត |
| អា. | និ. | អាយតនិបាត |

១ ទានសព្ទ

## គ - គ៍ - គរ

គ= គមនុស្ស - គសាងចេតិយ - គកើតជាភូមិ ។

គ៍= (ទិ.ស.) អ្នកក៏ទៅខ្ញុំក៏ទៅ - សើចក៏ដោយយំក៏ដោយ ។

គរ= (ដៃ) - លើកគរប្រណាម្យ (លើកកំបង់អញ្ជលីសំពះ) ។

គរ - គគរទឹក - គគរប្រេង - គគូរទឹក គគូរសម្ពកគូរ ។

គណ្ឌុរ គគេរគគារុងនៅក្បែរទ្វារ ។ បើគេកសាងគុដិ យើងក៏ត្រូវតែនាំគ្នាយោស្នាក់សាងព្រះវិហារមួយដែរ ហើយយើងទៅរកលោកទេពនិម្មិត ឲ្យលោកគូររូបទេពប្រណាម្យមួយទៀត ។

## គល - គល់ - គលហ

គល= (ម.ថ.គល់) - មាយា - មានពុត - ល្បិច -

ទាយគល - ធ្វើកិច្ចគល - ទាញគលគេ . . .

គល់= (សើមពីក្រោមឲ្យខ្ពស់ហើយឲ្យស្មើមិនឲ្យល្អៀង) -

គល់ដើមតុឲ្យស្មើ - យកកំណល់ដែលគល់នេះចេញ . . .

កលហ ឬ កលហ៍= (ម.ប. កល់លៈហៈ ឬ កល់) ជម្លោះ

កើតមានកលហនឹងគ្នា . . . ។

កាលណាស្រុកកើតកលិយុគ បណ្ដាជនរមែងតែងបែកសាមគ្គីពីគ្នា មានឧបាយកលផ្សេងៗ នាំឲ្យមានកលហ៍ពិរោធតែនឹងគ្នាឯងខ្លះជឿណាស់ខាងមន្តអាគម ខំប្រឹងរៀបកំណាល់គ្រូ ដាក់លើហ៊ឹងហើយថ្វាយបង្គំជាប្រក្រតី ដើម្បីឲ្យខ្លាំងពូកែមានជ័យជំនះ ។

## កា - កាណិ - ការ - ការណ៍

កា= កាខ្នងសំបុត្រ-កាទឹក (បំពង់សម្រាប់ដាក់ទឹក) ។

កាណិ= ព្រះកាណិ (ត្រចៀកស្ដេច) ។

ការ= ធ្វើការ-ការពារ-ការងារ-ការសូត្រ ។

ការណ៍=(ហេតុ, ដំណើរ) ចាស់ការណ៍-មានការណ៍ក្រណាស់ ។

ខ្ញុំមានការណ៍ធំណាស់ ខ្ញុំបានសរសេរសំបុត្រកាខ្នងផ្ញើទៅសុំច្បាប់ឈប់ធ្វើការបានប្រាំថ្ងៃ លុះការណ៍នោះបានសម្រេចហើយ ខ្ញុំនឹងវិលមកធ្វើការវិញ ។ ក្មួយស្រីខ្ញុំវាចេះការងារណាស់ វាការអម្បោះដាក់ខ្នារយ៉ាងស្អាតហើយវាអន្ទូងត្បាញធ្វើជាក្រមាគ្រប់ពណ៌ ។

## កេរ-កេរ្តិ៍ ឬ កិរ្តិ៍

កេរ = និយាយកេរគេ–បន់កេរកោះ (កេរក្លាយមកពីពាក្យកិរ្តិ៍) ។

កេរ្តិ៍ ឬ កិរ្តិ៍ = ស្រែកេរ្តិ៍របស់ខ្ញុំ – កេរ្តិ៍នេះបានមកពីជីដូនជីតា

ចែកឲ្យ ៗ កូនអើយកេរ្តិ៍មេបា បូលរក្សាគន់គិតគ្រង......

មាតាបិតាដែលទទួលមរណភាពទៅ តែងតែមានកេរ្តិ៍ទុកឲ្យកូនដូចជាស្រែចំការ គោក្របីជាដើម ហេតុនេះកូនត្រូវខំថែរក្សាកេរ្តិ៍ឲ្យគង់ល្អ បើមាតាបិតាទីទ័លក្រគ្មានរបស់អ្វីចែកឲ្យ ក៏កូនមិនត្រូវនិយាយសកេរអ្នកមានគុណដែរ ។

## កោដិ-កោដ្ឋ-កោត

កោដិ =(ម.ថ.កោត) ·១០ លាន–១កោដិ–៥កោដិ

កោដ្ឋ = (ជង្រុក – របស់សំរាប់ដាក់សព – ធាតុ) – កោដ្ឋមាស – ហ៊ុងសុវណ្ណកោដ្ឋ (កោដ្ឋមាស) – ទិញកោដ្ឋប្រាក់ដាក់ធាតុ.....

កោត = (ស្វែងស៊ើប)-កោតក្រែង កោតខ្លាច .... ។

សេដ្ឋីនេះកំណាញ់ណាស់ គេពុំសូវកោតញញើតទេ មានសម្បត្តិកោដិឃ្លាំងពុំហ៊ានទិញកោដ្ឋមាសដាក់ធាតុមាតាបិតា ។ សុវណ្ណកោដ្ឋ គឺព្រះមរណនាមនៃព្រះបាទសម្តេចព្រះនរោត្តម ។

## កុំ - កំ - កាំ - កម្ម

កុំ = (និ.ស.)-កុំទៅមក - កុំឲ្យ - កុំពោលពាក្យតាមកំហឹង ។

កំ = កំចាត់កំចាយ - កំណត់ - កំណើត - កំពង់ទឹក - កំពុងដេក - កំពុងបរិភោគអាហារ ។

កាំ = កាំជណ្ដើរ - កាំបិត - កាំរទេះ - កាំជ្រួច - កាំរនុះ - កាំភ្លើង - កាំភ្លោះ ។

កម្ម = (ម.ថ.កាំ) ទទួលតាមកម្ម - រងកម្មវេទនា - មានកម្មពៀរនឹងគ្នា - កម្មករធ្វើការឥតស្រាកស្រាន្ត ។

ត្រូវកំចាត់កំចាយកំហឹងកុំចងពៀរក្រែងមានកម្មវេរតទៅមុខៗ ។

កាំរនុះខ្លាំងពូកែជាងគ្រាប់កាំភ្លើងទៅទៀត ។

# ខណ្ឌ - ខន្ធ - ខាង់ ឬ ខ័ង

ខណ្ឌ =( សង្កាត់.ប៉ែក, កំណាត់, កំរិត ) ខណ្ឌជញ្ជាំង - ព្រោះគោល

ខណ្ឌព្រំបំការ - ស្វាយខណ្ឌស្ករ ឥតមានខណ្ឌទេ -

ព្រះរាជខណ្ឌ ។

ខន្ធ=(គង់ពួក, គំនរ, សេចក្ដីកំណត់) - ខន្ធ ៥ - ទំលាយខន្ធ

(ស្លាប់) រំលត់ខន្ធ (ចូលនិព្វាន) ។

ខាង់ឬខ័ង= ព្រះខាន់រាជ្យ, កើតរោគខាន់បៀត,

ខាន់លឿង, ខាន់ស្វាក, ខាន់ស្វា ។

ផ្ទះនេះគេបានបែកឲ្យកូនពីរនាក់ ខណ្ឌពាក់កណ្ដាលទឹងជញ្ជាំងក្ដារយ៉ាងសំខាន់ ។ រូបមនុស្សយើងមានខន្ធប្រាំ ព្រះខាន់រាជ្យដំកល់ទុកនៅព្រះបរមរាជវាំង ។ បុរសប្ដីប្រពន្ធនេះបានរៀបការអាពាហ៍ពិពាហ៍មានខាន់ស្លាពេញច្បាប់ ។ នៅខាងមុខប្រាសាទព្រះខាន់មានស្វាយខណ្ឌស្ករមួយដើម ។

មនុស្សនេះ កើតរោគខាន់លឿងយូរឆ្នាំណាស់មកហើយ នាំឲ្យខ្លួនទាំងឡាយទ្រុឌទ្រោមទាំងអស់ ពេទ្យបំណានមានជំរិះសំខាន់យ៉ាងណាក៏មើលពុំជា ។

## ក នឹង ខ

អក្សរ ក្ក-ម្ម-ល្ល-ស្ស- ទាំង ៤ តួនេះផ្ញើជើងនឹងអក្សរ ក នឹង ខ មានដូចគ្នា ហេតុនេះត្រូវចំណាំ ដើម្បីកុំឲ្យច្រឡំរបៀបផ្ញើជើងនឹងអក្សរពីរតួខាងលើនេះ ៗ

ក្ក=ក្កក់ក្កាញ់-ក្កុង ...

ខ្ក=ខ្កល់ខ្កើយ-ដាក់ខ្កោះ-ខ្កោសកោសដូង ...

ក្ម=កូនក្មួយ-ម្ដាយក្មេក-ក្មេងក្មាង ...

ខ្ម=ខ្មងត្រី-វេញខ្មាញ់-ខ្មាសអៀន-បិត្ដខ្មាំង ...

ក្ល=ក្លាហាន-ក្លៀវក្លា-ក្លិនក្រអូប-ក្លើម្រាក់-ក្លែងក្លាយ ...

ខ្ល=ខ្លារខិន-ខ្លាបខ្លួន-ខ្លែងហើរ-ខ្លៅល្ងង់ខ្លះ ...

ក្ស=មហាក្សត្រិយ៍-ក្ស័យជីវិត-ក្សិណក្ស័យ-ក្សេមក្សាន្ត
ទឹកក្សីរ-ក្សេត្រាធិការ ...

ខ្ស=ខ្សត់ខ្សោយ-ដីខ្សាច់-ខ្សឹកខ្សួលអួលព្រះទ័យ-ខ្សឹប
ខ្សាវ-ខ្សែក្រវាត់-ដក់ខ្សៀនាំគ្នាខ្សឹបខ្សៀវ ...

ម្ដាយក្មេកចូលទៅក្នុងផ្ទះ ហៅក្មួយស្រីឲ្យយកពូកខ្នល់ខ្នើយទៅហាលថ្ងៃ ៗ ចូរកុំខ្មាសអៀននឹងការសិក្សា រៀនចិត្តក្លាហានវេលាមានអាសន្ន ៗ ក្ដីខ្ញុំបានធ្វើខ្លួនបង្កើតមួយថ្វាយព្រះមហាក្សត្រិយ៍ ៗ មនុស្សខ្សត់ខ្សោយពុំសូវបានសុខក្រោមក្ដុនប៉ុន្មានទេ ៗ

---

# ពាក្យទំនឹមទំនៀមបុរាណ

– បេះមកពីរៀន មានមកពីរក ៗ

– តក់ ៗ ពេញបំពង់ ៗ

– សន្សំមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា ៗ

– រត់ឥតអំពើ ដើរអំណត់ចំរើនជាង ៗ

– បើខឹងឲ្យខំអត់ បើខ្សត់ឲ្យខំរក ៗ

– ងើយវាស្កក ឱនវាដាក់គ្រាប់ ៗ

– ចង់ពិសាឲ្យរកអន្ទក់ ចង់ស្រណុកឲ្យនឿយពីក្មេង ៗ

– ត្រកួន ៗ អ្នកស្រុកមើលងាយ រលាស់គូថខ្លាយមានទុកមានកាន់ ៗ

– ដូនមួយថ្លាយមានតក់មាននាឡិ ៗ

– សំដីជាឯក លេខជាទោ អក្សរជាត្រី ៗ

– ស៊ីព្រោះលោះកម្លាំង ៗ

- មនុស្សគេយកសំដី ដំរីគេយកភ្លុក ។
- សាប់មិនបានស៊ីយកឆ្អឹងញែក ។
- ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក ។
- អាគមផ្សំអាយុ ។
- ក្បួននៅហោរ ចោរនៅផាន ។
- ចេះដប់ពុំស្មើនឹងប្រសប់មួយ ។
- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ។
- សីលជាស្ពាន ទានជាស្បៀង ។
- រពឹសដៃ ផ្ទៃឆ្អែត ។
- កាប់បំពង់រង់ទឹកភ្លៀង ។
- កុំបោះសន្ទូចរំលងភ្នំ ។

## គ – គរ – គភ ឬ គ៌ភិ

គ = មនុស្សគ – ប្រាក់គ (ឥតសូរ) ។

គរ = ដើមគរ – សម្ដីគរ = យកគរញាត់ខ្នើយ – គរឲ្យខ្ពស់ធ្វើជាគំនរ – ប្រាក់មានគរគោក...

គភ៌= (ម. ថ. គ័រ) ស្រីមានគភ៌-ទ្រង់គភ៌ ។

ខ្ញុំឃើញស្រីគម្នាក់មានគភ៌ផង ដើររើសផ្លែគរទុំតាមមាត់អូរគរ ។

## គន់-គុណ-គុន

គន់= គន់មើល-គយគន់-គន់គូរ-បង្គន់ ឬ ប៉ាំងគន់....

គុណ= លេខគុណ-គុណធម៌-គុណមាតាបិតា-គុណនាម....

គុន= ហាត់គុនឲ្យស្ទាត់-គុនដាវ-គុនដំបង.....

មានគ្រូម្នាក់ចេះគុនដាវ គុនដំបង ហើយចេះទាំងគន់គូរមើល គូព្រេងទៀតផង គ្រូនេះមានគុណលើគេស្ទើរតែគ្រប់គ្នា ។

## គូ - គូរ

គូ= ន. ស្នាមភ្ជោះពទ្ធជុំវិញបន្ទាយ ឬ វាំង ។ ទៅមុជទឹកគូ....

គូ= ន. ចំនួនពីរផ្ទឹមគ្នា-មួយគូ-ព្រាបមួយគូ-គូកម្ម....

គូរ= កិ. ធ្វើឲ្យកើតជាគំនូរដំណាងរូបរាង សរពើ-គូររូប-គូរគំនូរ

កាលពីថ្ងៃអាទិត្យមុនខ្ញុំបានទៅមុជទឹកគូ ឃើញតាចាស់

ម្នាក់កំពុងតែគន់គូររកគូព្រេងឲ្យនាងក្រមុំម្នាក់អង្គុយនៅមាត់គូ ហើយតាទាយថាគូស្រករនាងឯងជិតដល់ហើយ ។

## គំ - គុម្ព - គុម ឬ គុំ

គំ= គំនាប់ - គំនិត - គំនូរ - គំនូសគូស - គំនុំ - គំពមគំពោះ...

គុម្ព= គុម្ពឈើ - គុម្ពឫស្សី - គុម្ពោត - ស្លឹកគ្រៃមួយគុម្ព...

គុម ឬ គុំ= គុំគួន - គុំព្យាបាទ - គុំបំផ្លាញ... ។

មនុស្សគ ឈរក្រោមដើមគរ ក្បែរគំនរអុស ។ គ្រូនេះបេះគន់គូរមើលរាសីបូកផ្សំថ្ងៃខែគុណលេខរហ័សណាស់ ។ បុរសនោះមានគំនិតអាក្រក់គុំព្យាបាទគេ កាន់កាំបិតទៅពួនសម្ងំនៅប្របគុម្ពឫស្សី ។

## កៀប - គាប

កៀប= រិតដោយដង្កៀប, ក្ដាមកៀបដៃ....

គាប= រិតដោយឃ្នាប ឬ គំនាប - គាបត្នោត - គាបមនុស្ស...

ប្អូនកុំលេងនឹងសត្វណាដែលមានដង្កៀបខ្លាចក្រែងវាកៀបដៃ ។

គេយកឃ្នាបគាបពោរស្ងួរយកចម្ហើយ ដូនកាលគេយកដំបៀត តៀត ត្របៀតកប្លកៀបសាច់ក៏សឹងមាន ។

## ក្រ – គ្រ

អ្នកសរសេរច្រើនច្រឡំពាក្យដែលចេញពី „ក្រ និង គ្រ„ ពីព្រោះធ្លាប់និយាយខុសខ្យល់អក្សរតាំងពីដើមមក លុះសរសេរក៏សរសេរតាមសព្ទដែលនិយាយនោះ ។

ក្រ= ក្របសៀវភៅ-ក្រាសសិតសក់-ក្រាស់ស្តើង-

ក្រិត្យក្រម - ក្រុបទ្វារ - សត្វក្រួច - មុខក្រៀមក្រោះ -

ក្រេវក្រោធ - ក្រោលក្របី...

គ្រ= គ្របពាង - គ្រាប់ឈើ - គ្រោះថ្នាក់ - ស្ទឹកគ្រែ... ។

ត្រូវយកក្រដាសក្រាស់ធ្វើក្របសៀវភៅការពារកុំឲ្យឆាប់រហែក ។ កាលណាសិតសក់រួចហើយ ត្រូវទុកដាក់ក្រាសទីងស្និតក្នុងប្រអប់គ្របឲ្យជិតកុំឲ្យធូលីចូលបាន ។ បងខ្ញុំមានគ្រោះថ្នាក់ក្រាស់គ្រែ អាចោរចង្រៃវាចូលលួចក្របីអស់ពីក្នុងក្រោល គាត់ក្រេវក្រោធកើតទុក្ខមុខក្រៀមក្រោះ ។

## ង - ងរ - ងា - ងារ

ង =ទូកង - ពត់ឈើឲ្យងបុង - ក្អកងងឹត - ងងុយដេក.....

ងរ =(សំដែងអាការមាយា ) នាំងរ ស្រីងរច្រើន...

ងា = ងាដៃងាជើង-ងាដៃជន្លេង...

ងារ =( មុខងារ )ការងារ- ងារមន្ត្រី ដមួយងារ -សួងងារ... ។

អ្នកអង្គុយលើក្បាលទូកង ងាដៃទៅមុខទៅក្រោយ ខ្លះប៉ិនប្រសប់ បានងារការកុងរបៀបអុំប្តូរទូកនោះផង ។ ស្រីនេះចិត្តសាវា ងរចុះងរ ឡើង សួងងារឲ្យគេពល់តែឆ្នាំ ។

## ច - ចរ

ច = ឆ្នាំច (ឆ្កែ) ចឈើ ( ពុះឈើ )....

ចរ = ចរព្ទោះទៅ -ចរយាត្រា -ចរចានឹងគ្នា -ចរណៃ......

កាលពីឆ្នាំច ព្រះមហាក្សត្រិយ៍ទ្រង់បានចរលើណាទៅកាន់ប្រទេស លាវ ដើម្បីចរចាការណ៍សុខទុក្ខកង់ព្រះនគរ ។

## ចារ-ចារុ៍-អាចារ-អាចារ្យ

ចារ= ចារសាស្ត្រា ដើមចារផ្កាក្រហម សុភាចារបុរស ធ្វើ

ចំណារចាររបង ....

ចារុ៍= (ម.ថ.ចា) ចារុ៍មាស ចារុ៍ប្រាក់ បុរាណពប់ការចារុ៍ ....

អាចារ= មានអាចារល្អ (បុគ្គល - មារយាទ - ចរិយា)

អាចារ្យ= អាចារ្យវត្ត - អាចារ្យយោគី ....

គេចារសាស្ត្រានឹងដែកចារ ៗ អ្នកចំការចាររបងព័ទ្ធជុំវិញសួនច្បារ ៗ នារីនេះពាក់ចារុ៍មាស មានអាចាររម្យទម ៗ លោកសុភាចារបុរសបានគោះហៅអាចារ្យយោគី អំពប័ភយអ្នកស្រុកឲ្យយកតែអុសចារបូជាខ្មោច ៗ

## ចិត-ចិត្ត-ពិចិត្រ ឬ វិចិត្រ

ចីត= ចិតខ្មៅដៃ-ចិតក្របក-ចិតនឹងកាំបិតមុត

ចិត្ត= ចិត្តល្អ ចិត្តមានអារម្មណ៍ ចិត្តឃោរឃៅ ....

ពិចិត្រ ឬ វិចិត្រ= ដែលរំលេចឬឆ្លាស់ក្បាច់រចនាឬល្អប្លែក)

ក្បាច់វិចិត្រ – ខំវិចិត្រឲ្យល្អប្លែក...។

កុមារនេះ ខំយកចិត្តទុកដាក់ទឹងការសូត្ររៀនណាស់ ដល់ពេលគ្រូគំនូរក៏យកខ្មៅដៃដែលចិតទុកយ៉ាងស្រួចមកគូរឲ្យល្អវិចិត្រ ។

ចោត-ចោទ

ចោត= ច្រាំងចោត – ដីចោត – ចំណោតភ្នំ...

ចោទ= សួរចោទ - សេចក្ដីចោទ - ដោះចំណោទដែលគេចោទ..

មានអ្នកប្រាជ្ញម្នាក់សួរចោទថា ពីព្រោះអ្វីបានជាច្រាំងទន្លេមានកន្លែងខ្លះចោតចុះទៅកំពង់ពុំបាន កន្លែងខ្លះទេរចុះឡើងបានដោយងាយ ចូរដោះស្រាយចំណោទនេះឲ្យបានពិស្ដារ ។

ព្រាង – ច្រាំង – ជ្រាំង

ព្រាង= បន្ទាព្រាង–សម្រាប់ប្រុសស្រីច្រូងព្រាង...

ច្រាំង= ច្រាំងទន្លេ – ច្រាំងសមុទ្រ – ច្រាំងចោត – ច្រាំងទេរ

ជ្រាំង = កើតជ្រាំងពេញមាត់ - ជ្រាំងខ្ទរសម្ល... ។

តាមប្រាំងទន្លេ អ្នកនេសាទត្រីដោតសម្រាស់ប្រូងប្រាង ។ ទារកនេះ កើតជ្រាំងពេញអណ្ដាតសក្បុសដូចដីឥដ្ឋនៅមាត់ប្រាំងទន្លេកំពង់ឆ្នាំង ។

**ឆ្មា - ឆ្មារ**

ឆ្មា = ឆ្មាស្រុក - ឆ្មាបា - ឆ្មាជាសត្វចតុប្បាទសត្រូវនឹងកណ្ដុរ... ។

ឆ្មារ = ខ្សែឆ្មារ - សរសៃអម្បោះឆ្មារ - ក្រូបឆ្មារ... ។

ឆ្មាជាសត្វចតុប្បាទចាប់កណ្ដុរបរិភោគជាអាហារ ពោមព័ឆ្មារ ទន់ដូចសម្លីកប្បាស ។

**ឆ្លាត - ឈ្លាស - ឆ្លៀត - ឈ្លៀស**

ឆ្លាតឬឈ្លាស -គុ. (ប៉ិនប្រសប់-ស្ទាត់) ប្រាជ្ញាឆ្លាតឬឈ្លាស- មនុស្សឈ្លាសឬឆ្លាត- ឈ្លាសវៃ...

ឆ្លៀត - កិ. (រំលែកពេលឬលួចរបក់ធ្វើកិច្ចការអ្វីៗ) ឆ្លៀតធ្វើការផ្សេងទៀតផង - ធ្វើការរាជការផង ឆ្លៀតធ្វើជំនួញផង ។

ឈ្លៀស– កិ. ( ស្ទាត់គេណ្ឌាយកមនុស្សឬសត្វមកប្រើជាពលការ

បណ្ដើរសិន ) ឈ្លៀសមនុស្ស ( ស្ទាត់គេណ្ឌាមនុស្ស )

ឈ្លៀសគោរទេះ...

មានមេឃុំម្នាក់រ័យនៅក្រុង ធ្វើការពលការធ្ងាតវៃណាស់ ហើយ

ធៀតធ្វើការងារបំពាំមជីវិតខ្លួនឯងផង បើមានការធ្វើថ្នល់កន្ទុម្ពមង ៗ

ដោយប្រញាប់ប្រញាប់ មេឃុំឈ្លៀសអ្នកស្រុកឲ្យលើកថ្នល់ភ្លាម ៗ

## ឆ្វេង – ឈ្វេង

ឆ្វេង = ន. (ទីទៃពីស្តាំ) ខាងឆ្វេងដៃ មនុស្សឆ្វេង (មនុស្ស

ធ្វើការអ្វីៗមិនចុះថែប)

ឈ្វេង = គុ. (ថ្លាជ្រះឥតមន្ទិល) ទឹកថ្លាឈ្វេង... ៗ

កិ. ឈ្វេងយល់ (រំពឹងគិតយល់ដោយប្រាជ្ញាជ័ថ្វា) ៗ

មនុស្សមានប្រាជ្ញាឆាប់ឈ្វេងយល់ការណាស់ បើមានការណ៍អ្វី

កម្រ ខំរំពឹងគិតដោយហ្មត់ចត់ទើបបានធ្វើ មិនធ្វើបំពាក់បំពានខុស

បបបទដូចមនុស្សឆ្វេងនោះឡើយ ៗ

## ជរ - ជូរ - ជួ - ជួរ

ជរ= ហូលជរ–ជរជាយ–សំពត់មានជរ

ជូរ= អម្ពិលជូរ–សម្លម្ជូរ....

ជួ= មនុស្សជួ–ជួជង–អាក្រក់ជួជាតិ....

ជួរ= ឈរជាជួរ - ជួរភោគ–ជួរដំបូរ... ។

សម្លណាមានរសជាតិជូរ ហៅថាសម្លម្ជូរ ។ ឪពុកក្មេកឃើញកូនប្រសាស្លៀកហូលជរដើរលេង ឥតមានគួរសមនឹងញាតិសន្តាន ក៏ត្អះតិះដៀលថា អានេះជួជងណាស់ ប្រហែលជាគាត់ទៅជួរខាងម្តាយវា ។

## ជុំ - ជំ - ជាំ

ជុំ= ដើរមួយជុំ – ប្រទក្សិណបានបីជុំ – ទីប្រជុំ...

ជំ= ជំទាវ – ជំនន់ – ជំនួញ – ជំនុំជំរះ – សំពត់ជំនិ...

ជាំ= មុខជាំ – ក្រហមជាំ – ដីជោកជាំទឹក... ។

វេលានោះ គេប្រជុំគ្នានៅសាលាស្រុក លុះរាស្ត្របានមកជួបជុំគ្នា

ហើយទើបគេជំនុំគ្នាពីផ្លូវជំនួញផ្សេងៗ ។ ហៅក្រុមជំនុំជំរះរឿងជំទប់ជុំ ដែលគេកាយជាំមុខ ។

## ញុះ - ញោស - ញោះ

ញុះ= ញុះញង់ - ញុះញយ។...

ញោស= ស្វាយទុំញោស - ហស់ញោស - ស្ពឺដេរ

បន្ទោសញោសពេកណាស់...

ញោះ= ញោះមួយដំបង - ញោះមួយមាត់ប្រឡោតតូង... ។

កុំញុះញង់គេឲ្យឈ្លោះគ្នា កំហឹងជ្រុលញោសពេកនាំឲ្យមានទុក្ខធំ ។ មនុស្សចិត្តស្រាល បើគេញោះតែមួយមាត់ខឹងប្រលោតមួយរំពេច ។

---

## ពាក្យទំនឹមទំនៀមបុរាណ

- គេខុសកុំអាលអរ គេសាទរកុំអាលអួត
- ជាងមិនកើតទៅបន្ទោសដែក
- នៅស្រុកឲ្យស្រាស់បន្ទា អារសាច់ជូនខ្លាទើបនៅស្រុកបាន
- ផ្កែខាំឲ្យរកម្ចាស់ គោឆ្កេះឲ្យរកនាយ

- នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយជាមួយ
- ស្អប់កុំឲ្យបាញ់ ស្រឡាញ់កុំឲ្យខ្ចី
- ទឹកជោរត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី
- គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ
- រហ័សតែមាត់ ត្រគាកស្លាប់ស្ដូក
- ឮផ្គរកុំអាលចាក់ទឹកចោល
- កុំយកមេឃក្រាប់អង្គុយ
- បើមិនជួយចូកជួយចែវ កុំយកជើងរាទឹក
- ញៀននៅចុក ទំពក់នៅដៃ
- គោកៗស៊ីកតែមាត់ត្រដោក ផ្អួតតែពោះក្របី
- ឈើកោងវល្លិ៍ព័ទ្ធ មនុស្សស្រាតព្រាតកុំយកជាគ្នា
- គោដំបៅខ្លួន ក្អែកហើររំលង រំសាយកន្ទុយ
- ក្អែកមួយជាក្អែកដប់
- ទូកបែកជាទូកគត់ ទូកកំបុតជាទូកង
- ទូកទៅ កំពង់នៅ
- ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន
- ឃ្លោកលិច អំបែងអណ្ដែត

## ដ – ដ៏ – ដរ

ដ = ទូកដ កំពង់ដ-ជូនដ

ដ៏ = ទ. ទ្រព្យដ៏ប្រសើរ – គុណដ៏ឧត្ដម-ធម៌ដ៏បវរ

ដរ = បួសដរ-ដំបៅដរ រកស៊ីទាំងត្រដរ ។

ពាណិជនេះមានធនធានដ៏ប្រសើរ បានជិះទូកដទៅស្រុកគាត់ ត្រូវខ្យល់ព្យុះបោកលិចទូក ខំប្រឹងត្រដរហែលទាល់តែដល់ត្រើយ ។

## ដុស – ដុះ – ខុស

ដុស = ដុសក្អែល-ដុសលាង ដុសខាត់-ដុសធ្មេញនឹងច្រាស់...

ដុះ = ស្រូវដុះពន្លក-ដីដុះខ្ពស់ – រកស៊ីដុះដាល....

ខុស = សរសេរខុស-ធ្វើលេខខុស-សេចក្ដីខុស ។

ខុសហើយឯង ហេតុអ្វីបានជាយកគោទៅបនឲ្យត្រដុសគ្នាលើដំណាំកំពុងតែដុះល្អខ្ទេចខ្ទីអស់ ។

## ត នឹង ថ

ចូរប្រយ័ត្នជើងជើងអក្សរ «ប្ប - ល្ល» ទីងតួអក្សរ «ត - ថ» ។

ជើង «ប្ប» ត្រូវនៅក្រោម «ត» មិនត្រូវនៅក្រោម «ថ» ទេ៖

...ាញ - ត្បាត្រចៀក - ត្បាល់កិន - ត្បុតត្រី - ត្បុលបូលខាងត្បូង - ...ងខ្មៀយ - ម្ចាស់ជីវិតលើត្បូង - ត្បូងពេជ្រ...

ជើង «ល្ល» ផ្ញើទីងតួអក្សរ «ត» មានពាក្យតិចណាស់ ដូចជា៖ ...ករបាំ - វាលត្លុងត្លុវតតព្រៃ ក្របត្លុងមូលត្លុ ។ ក្រៅពីនេះជើង «ល្ល» ផ្ញើទីងតួ «ថ» ទាំងអស់៖ ថ្លស់ផ្លោយ - ទឹកថ្លា - ថ្លាងធំ - ថ្លឹងមាស - ...កត្រពាំង - ថ្លៃថ្នូរ - កូនថ្លោស - ថ្លោសចិត្ត...

អក្សរ «អ» ត្រូវនៅក្រោម «ត»៖ រងឹត្អឹង, ត្អូញត្អែរ, កូនក្មេងត្អើក

## បេះ - បំណេះ - ត្រិះ - គិរិះ - ជិរិះ

បេះ= បំណេះ មនុស្សបេះ, កុមារនេះមានបំណេះគ្រាន់បើ ...

ត្រិះ - គិរិះ - ជិរិះ= ទ្រង់ត្រិះរិះ, ទ្រង់ព្រះជិរិះ, (ទ្រង់គិត) លោកមានជិរិះល្អ (មានសេចក្តីរិះគិតត្រូវ)...

មនុស្សណាមិនចេះអក្សរគេទុកដូចជាមនុស្សខ្វាក់ ។ ត្រូវខំត្រ
ស្វែងរកចំណេះវិជ្ជាទាន់វ័យនៅក្មេង ...

## ត្រៀប - ទ្រាប

ត្រៀប= កិ.វិ. ដែលដេរជាសដោយមានរបៀប ។ ឈរត្រៀ
មើលទៅឃើញត្រៀប - មនុស្សឈរត្រៀបត្រា ...

ទ្រាប= ន. ឬកិ. ទ្រាបបាយផ្អែម ទ្រាបល្អ ។ ទ្រាបស
ពីលើ - ទ្រាបលើស្មា ។

មានគេធ្វើបុណ្យត្រៀបត្រាក្នុងវត្ត មានសិស្សលោកម្នាក់ដើរ
គេដួលទ្រាបលើសម្លនិងទ្រាបបាយដែលគេប្រគេនលោកកំពប់អស់

## ថ្មារ - ថ្មើរ

ថ្មារ= ពេល កាល សព្វថ្ងៃច្រើនប្រើ "ថ្មើរ" វិញ ថ្មើរមានហើ
យប់ថ្មើរណេះហើយទៅពុំបានទេ

ថ្មើរ= ថ្មើរជើង ទាហានថ្មើរជើង (ពលដើរដោយជើ
ថ្មើរព្រៃបរបាញ់សត្វក្នុងព្រៃភ្នំ ... ។

មកដល់ទីនេះថ្មើរម៉ោង   អ្នកឃើញពលថ្មើរជើងមកហើយឬនៅ ។

## ទ - ទរ - ទា - ទារ

ទ= ទត្រងទឹកភ្លៀង, ទឹកហូរតាមទស័ង្កសី....

ទរ= (ជេរស្តីបន្ទោស) កូនសិស្សខ្ជិលគ្រូទរសន្ទឹក...

ទា= សត្វទាឈ្មោលញី, ទាញទទះស្លាបហែលទឹក

ទារ= ទារប្រាក់ថ្លៃផ្ទះ, ទារប្រាក់ថ្លៃទា, ជំទប់គីនទារប្រាក់ពន្ធថ្លៃដី ។

ប្តីទរប្រពន្ធសន្ទឹក   ពីព្រោះស្តោះទឹកមាត់ទៅលើទត្រងទឹក ។

ព្រឹកស្អែកខ្ញុំទៅទារប្រាក់ថ្លៃទាអំពីជង្ហៅទា ។

## ទាន - ទៀន

ទាន= ធ្វើទាន - ឲ្យទានបាយសម្ល - សូមទានមេត្តាប្រោស...

ទៀន= ទៀនធូប - អុជទៀនជ័យ - លក់ទៀនវស្សា.....

លោកតាគាត់ទៅសមាទានសីលឯវត្ត   ដៃកាន់ជើងពានមានផ្កានិងទៀនធូប ។

## ទស់ - ទោស - ទោះ

ទស់= (ពាំងទប់) ទប់ឆ្នស់ក្នុងព្រែក ទស់ទប់ឲ្យជាប់......

ទោស= ទោសធ្ងន់ – កាត់ទោសសម្លាប់ – ទោសពៃរ៍ –

សូមអភ័យទោស......

ទោះ= ទោះល្អក្តីអាក្រក់ក្តី – ទោះបីខុសត្រូវដូចម្តេច......ៗ

ជនល្មើសត្រូវមានទោសពិន័យជាប្រាក់មួយពាន់រៀល អំពីប្រព្រឹត្តខុសនឹងបញ្ញត្តិ ៗ សេចក្តីនេះទោះបីលើសលស់ក្តាំក្តងយ៉ាងណា សូមមេត្តាអភ័យទោស ៗ

## ទាប - ទៀប

ទាប= ដីទាប – ពងទាបទ្រនាប់ – កិរិយាពបទាប....

ទៀប= ទៀបនឹងដល់ – ទៀបភ្លឺ – ទៀបកោះ – ផ្ទះទៀបខ្ញុំ –

ទៀបដាក់ចំណីអាហារ.... ៗ

កុមារនេះមានកិរិយាសុភាពរាបសាគួរសមណាស់ បានផ្លែទៀបទុំ ដាក់ក្នុងទៀបសំរឹទ្ធិកណ្ដៀតយកទៅជូនអ្នកគ្រូបង្រៀន ។

| ទ្រព្យ – ទ្រាប់ – គ្រប់ |
|---|

ទ្រព្យ = ន. វត្ថុ–ធនធាន–សម្បត្តិ ។ ថែទាំទើបគង់ទ្រព្យ ។

ទ្រាប់ = កិ.–រង–គលពីក្រោម ។ ទ្រាប់ធ្វើជាទ្រនាប់......

គ្រប់ = ន.-ឈ្មោះដំណាំមានផ្លែបរិភោគជាបន្លែឬអន្លក់

គ្រប់ពុតលំញង–គ្រប់ក្រាមរមាស....... ។

យាយគ្រប់គាត់មានទ្រព្យសម្បត្តិច្រើន គាត់យកស្លឹកចេកទ្រាប់បាតកញ្ជើដាក់ផ្លែគ្រប់ពេញ ទូលទៅលក់ឯផ្សារ ហើយគាត់ទិញបានត្រីកន្ត្រប់មួយគូ ។

| ធន – ធន់ – ធុន |
|---|

ធន = ម.ថ. ធន់– ទ្រព្យសម្បត្តិ–ធនធាន–ទ្រព្យធន

(កុំសរសេរយ៉ាងនេះ៖ ធន់ធាន).....

ធន់ = (ទ្រាំ, អត់, ធ្មត់, ស៊ូ) ធន់ជម្ងឺ – ធន់រងា...

ធុន = (បែបយ៉ាង, កំណើតដូចគ្នា) បានមួយធុន – កែវមួយធុន – មនុស្សមួយធុន... ។

ពាណិជម្នាក់មានទ្រព្យធនធានច្រើនណាស់ ប្រឹងធ្វើការមិនដឹងយប់-ថ្ងៃ ធន់ក្តៅធន់ត្រជាក់ មនុស្សធុននេះ ពុំសូវមានច្រើនទេ ។

ធុំ – ធំ

ធុំ = (ក្លិន)– ធុំក្រអូប – ធុំអាក្រក់ – ធុំក្លិនសាយ...

ធំ = (ទីទៃពីតូច) ផ្ទះធំទូលាយ – សាលាធំ – ឪពុកធំ – ធំប្រុសធំស្រី ។

កាលប្អូនខ្ញុំនៅតូចវាស្មោកគ្រោកណាស់ ខោអាវវាកខ្វក់ធុំក្លិនអសោចិ៍ លុះដល់វាធំឡើង ចូលទៅរៀនឯសាលាវាស្អាតជានិច្ច

ទប់ – ទព្វ

ទប់ = ស្នែងទប់ – លើកទំនប់ទប់ទឹក...

នព្វ = (ប្រាំបួន – មាសនព្វគុណ (មាសទឹក៩) – នព្វគ្រោះ (ឈ្មោះផ្កាយគ្រោះ៩) នព្វន្ត (វិជ្ជាលេខមាន៩) លេខនព្វន្ត – ក្បួននព្វន្ត.... ។

មានអ្នកស្រែម្នាក់កំពុងតែលើកទំនប់ទប់ទឹក ឃើញកុមារម្នាក់ដើរ កជិតក៏សួរថា នាងឯងចេះក្បួននព្វន្តឬទេ បើចេះចូររកថ្លៃស្នងទប់១៥ ត្រូវជាប៉ុន្មានរៀល បើស្នង ២ ថ្លៃ ២៨រៀល ។

## នូវ – នៅ

នូវ = (ម.ថ.នៅ) និ. នឹងហើយនឹងៈ មាតាបិតានឹងបងប្អូននូវមាមីង ទាំងអស់ ។

អា.និ. (ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើ) នឹងបាននូវផល ល្អ–អ្នកនឹងសម្រេចនូវវិជ្ជាដ៏ប្រសើរ សិស្សប្រព្រឹត្តនូវអំពើល្អ... ។

នៅ= កិ. នៅផ្ទះនៅក្នុងបន្ទប់ – អស់ហើយឬនៅ – នៅឡើយ ។ សិស្សទាំងឡាយ ចូរអ្នកខំប្រឹងសូត្ររៀន ឲ្យបានសម្រេច នូវចំណេះវិជ្ជា ដ៏ប្រសើរទាន់ខ្លួនអ្នកនៅក្មេង ។

## បា – បារ – បិត – បិទ

បា = នៃបា – ហៃបា – មេបា – គោបា – ក្របីបា...

បារ = បារដឹកទំនិញ – ក្រុងបារយ៉ំយប់..,

បិត = បិតផ្ដៅ – បិតឈើស្រួច – បិតស្រោ...

បិទ = បិទទ្វារ – បិទមាស – បិទមុខ បិទបាំង ។

ឪពុកទៅបា៉មានគោបាមួយធំ ខ្ទង់ដំបារ យកទៅលក់ឲ្យបិនបិតស្រោ នៅទន្លេបិទជិតផ្សារកំពង់ចាម ។

## បូ – បូរ – បូពិ

បូ = ចងបូ – សក់ចងបូ...

បូរ = បូរបាច់ – និយាយបូរបាច់ប្រាប់គេ...

បូពិ = ទិសបូព៌ាឬទិសបូពា៌ (ទិសខាងកើត)

កាលពីថ្ងៃអាទិត្យ មានកុមារីម្នាក់ដើរមកពីទិសបូព៌ា ចងបូសក់យ៉ាងស្រស់ មុខរីករាយ ហើយឈប់និយាយបូរបាច់នឹងនារីម្នាក់នៅក្បែរផ្សារត្រី ។

## បាត - បាត្រ - បាទ

បាត =( ផ្នែកខាងក្រោមនៃដំណៅផ្ទៃដៃ - ជើង ) បាតដៃ

បាតបឹង - បាតខ្ទះ - ប្រសជ្ជីបាត - បិណ្ឌបាត...

បាត្រ =(ភាជនៈ) = បាត្រលោក - បាត្រដែក - ស្បោកបាត្រ

បាទ (ជើង) - ព្រះបាទ - ប្រាក់បាទ - ក្រាបទៀបព្រះ

បាទា - សត្វបតុប្បាទ...

ប ជើង ដ្ឋ មានពាក្យតែ ៤ ម៉ាត់ = ប្ដី - ប្ដឹង - ប្ដូរ - ប្ដេជ្ញា ។

ម្ដាយខ្ញុំបាទគាត់បានផ្ញើប្រាក់ទៅទិញបាត្រមួយ នៅស្រុកសៀមថ្លៃ ម្ភៃបាទ ពងឈើ បាតរាបស្មើដូចជាបាតខ្ទះ ទុកប្រគេនលោកបងខ្ញុំដាក់បង្ហាន់បិណ្ឌបាត ។

## បំភាស - បំភាស់ - បំភះ

បំភាស ឬ បម្រាស = កិ. ធ្វើឲ្យប្រាស ឲ្យឃ្លាតចេញ

ប្រាសព្រាត់....

បំរាស់ ឬ បម្រាស់ ពាក្យសម្រាប់និយាយផ្ទុយនឹងពាក្យបំរើ

បំរើបំរាស់ គឺទទួលភារៈតាមកិច្ចដែលគេប្រើប្រាស់....។

បំរះ ឬ បម្រះ ឬ បង្រះ = បំរះនទៀល - ប្រះប្រាណនទៀល ទៅមករឿយ ៗ ៗ

កុមារនេះខំបំរើបំរាស់មាតាណាស់ លុះដល់មាតាប្រាសព្រាត់ចោល ទៅក៏យំប្រះប្រាណនទៀល សោកស្តាយមាតាឥតមានល្ហែឡើយ

## បះ - ប៉ះ - បាស

បះ = ក្តារបះបុងខ្មាង - បះបោររឹងទទឹង - នាំគ្នាបះឈប់ធ្វើការ

ប៉ះ - ប៉ះទង្គិច - ប៉ះសំពត់ភ្លាប់ - ទឹមគោប៉ះគ្នា - ប៉ះមុខគ្នា - ប៉ះពារ - ប៉ះពាល់...

បាស = (អម្បោះចងសំពត់ស្នប) - ខ្សែបាស - បន្ទុស៊ឹកបាស

«បាស់ សរសេរដូចនេះគ្មានទេ» ។

ថ្ងៃមួយ នៅស្រុកមាខ្ញុំ មានមនុស្សបះបោរផ្អើលឆោឡោរត់ប៉ះទង្គិចគ្នា ខ្លះភ័យរត់បុះទឹក ខ្លះរត់ទៅពួនសម្ងំក្នុងកន្ទ្រុបវល្លិបាស ។

## បង្កាន់ - ប្រកាន់

បង្កាន់ដៃ = ន. បង្កាន់ដៃស្ពាន - សំបុត្របង្កាន់ដៃ...

ប្រកាន់ = កិ. ប្រកាន់ទោស - ប្រកាន់ពូជបក្ខ... ។

កាលពីថ្ងៃមុន ខ្ញុំបាទបានបង់ពន្ធអាករប៉ូលហើយ មានទាំងបង្កាន់ដៃសំគាល់ទៀតផង ឥឡូវនេះមានគេមកប្រកាន់ថាខ្ញុំបាទពុំទាន់បង់ពន្ធនោះទេ ។

## បញ្ញត្ត - ប្រព្រឹត្ត - បញ្ញត្តិ - ប្រព្រឹត្តិ

បញ្ញត្ត - ប្រព្រឹត្ត = (កិ. គុ.) រាជការបញ្ញត្ត - ប្រព្រឹត្តទុច្ចរិត - មានច្បាប់បញ្ញត្ត - សិស្សប្រព្រឹត្តសុចរិតត្រឹមត្រូវ...

បញ្ញត្តិ - ប្រព្រឹត្តិ = (ន.) មានបញ្ញត្តិ - ការប្រព្រឹត្តិ - ខុសនឹងបញ្ញត្តិ - សេចក្តីប្រព្រឹត្តិ - ត្រូវធ្វើតាមបញ្ញត្តិ...

សិស្សល្អ ប្រព្រឹត្តសុចរិតតាមបញ្ញត្តិ ។ មានព្រះរាជប្រកាសបញ្ញត្តដល់មនុស្សទុច្ចរិតឲ្យខំប្រព្រឹត្តត្រឹមត្រូវ ។ ការប្រព្រឹត្តិល្អឥតមានខុសនឹងបញ្ញត្តិ នាំឲ្យបានសុខគ្រប់ប្រការ ។

" ចូរចំណាំពាក្យពីរម៉ាត់ខាងលើនេះ បើជាកិរិយា ឬគុណនាមត្រូវសរសេរ "ត្ត" បញ្ញត្ត, ប្រព្រឹត្ត បើជានាមវិញ ត្រូវសរសេរ "ត្តិ" បញ្ញត្តិ ប្រព្រឹត្តិ

## ប្រណិប័តន៍ – បដិបត្តិ ឬ ប្រតិបត្តិ

ប្រណិប័តន៍ = ន. (ការសំដែងសេចក្ដីគោរព – ការគំនាប់ ឬសំពះ) សូមក្រាបប្រណិប័តន៍ ចូលមកលោក...

បដិបត្តិ ឬ ប្រតិបត្តិ = (ម.សំ.) (ការប្រព្រឹត្ត – កាន់ – ធ្វើតាម) សេចក្ដីបដិបត្តិ – ត្រូវប្រតិបត្តិតាមច្បាប់ ។

អ្នកត្រូវប្រណិប័តន៍ចាស់ព្រឹទ្ធាចារ្យវេលាអ្នកជួបប្រទះតាមផ្លូវ ។ នៅសាលារៀនត្រូវគោរពប្រតិបត្តិគ្រូកុំបីឲ្យខ្វះ ។ បើចេះធម៌ចេះច្បាប់ត្រូវតែបដិបត្តិតាមទើបបានប្រសើរ ។

## ប្រឹក្សា – ព្រឹក – ត្រឹក្សា

ប្រឹក្សា = ការពិចារណា – ពិគ្រោះគ្នា – ប្រឹក្សាគ្នា ...

ព្រឹក = ព្រឹកព្រហាម – ព្រឹកស្អែក – ព្រឹកល្ងាច ...

ព្រឹក្សា = ឈើទាំងពួង ព្រៃព្រឹក្ស-ពោធិព្រឹក្ស... ។

ព្រឹកស្អែកនេះ រដ្ឋាភិបាលនឹងប្រឹក្សាសម្រេចអំពីផលដែលបានមក ព្រឹក្សជាតិទាំងឡាយក្នុងប្រទេសកម្ពុជា ដើម្បីនឹងកម្រិតពន្ធដារតាម ញាតិ ។

ប្រៀប - ព្រាប - ព្រៀប

ប្រៀប = ប្រៀបធៀបប្រដូច-ប្រៀបផ្ទឹម-និយាយប្រៀបប្រាយ...

ព្រាប = ព្រាបយំថ្ងូរ-ព្រាបសប្រផៃះ...

ព្រៀប = ទឹកជន់ព្រៀបច្រាំង-ពេញព្រៀបមាត់ឆ្នាំង... ។

លុះដល់ខែវស្សា ស្រះវត្តយើងមានទឹកពេញព្រៀបហូរហៀរ ប្រៀបដូចជាទឹកទន្លេឡើងលិច មានព្រាបឈ្មោលញីហើរព្រាតព្រោង រកស៊ីនៅលើមាត់ស្រះឥតមានស្រាកស្រាន្ត ។

ប្រុស - ប្រុះ - ប្រេះ - ប្រោស - ប្រោះ

ប្រុស = (បុរស) កូនប្រុសស្រី-ក្មួយប្រុស...

ប្រុះ = ភ្លឺប្រុះព្រោងព្រាយ ភ្លឺប្រុះធ្លុះឡើង...

ប្រេះ = កើតទុក្ខស្ទើរប្រេះទ្រូងស្លាប់–ផ្លែឈើទុំប្រេះ...

ប្រោស = ប្រោសសត្វ–ទានប្រោស–សូមប្រោសប្រណី យកគ្នាទៅប្រោស...

ប្រោះ = ប្រោះទឹក, ប្រោះត្រី, មើមប្រោះ, ប្រោះឲ្យមានជីវិត..

តាំងតែពីកូនប្រុសនោះធំឡើងកាលណា ម្ដាយកើតទុក្ខស្ទើរប្រ ទ្រូង វេលាយប់វាទៅលួចត្រីដែលគេប្រោះទុកបរិភោគ ដូចកាលវាតា គ្នាយកទៅប្រោសពោលឥតមានមេត្តា ។

**ប្រេង – ព្រេង**

ប្រេង = ន. ប្រេងកាត – ប្រេងដូង – ប្រេងល្ង – លាបប្រេង

ព្រេង = គុ. បុរាណ – គូព្រេង – ទ្រព្យព្រេង – ពាក្យ ព្រេង – ព្រេងព្រឹទ្ធ.... ។

នៅស្រុកស្រែចំការ គេអុជប្រេងកាតឬខាញ់ត្រី ភព្វព្រេងតែក នៅទីក្រុងធំៗ មានភ្លើងអគ្គិសនី ភ្លឺប្រុះធ្លុះគ្រប់គេហដ្ឋានទាំងអស់

## ផ្សា - ផ្សារ

ផ្សា = ផ្សាខ្ទាប - ផ្សះផ្សាគ្នា - ថ្នាំដំបៅនេះផ្សា....

ផ្សារ = ផ្សារផ្សា - ទៅលេងផ្សារ - ផ្សារនេះស្គុកស្គម - ផ្សារ
ភ្ជាប់ឲ្យជិត - ផ្សារបង្កៀងនឹងទឹកបន្សារ... ។

កាលពីថ្ងៃសៅរ៍មុន មេឃុំបានផ្សះផ្សាអ្នកលក់បន្លែនៅផ្សារ អំពី
ឈ្លោះវាយគ្នា មានរបួសឈឺផ្សា ជាប់ទាំងជាងផ្សារម្នាក់ធ្វើជាសាក្សី
ទៀតផង ។

## ព - ពរ - ពារ - ពៀរ

ព = ស្រីពកូន - ពពោះ - ពគំនរទុក...

ពរ = ឲ្យពរ - ទទួលពរសព្ទសាធុការ - ពរជ័យ...

ពារ = ការពារ - ពាររបង - ដើរពានពារលើគល់ឈើ...

ពៀរ = ចងពៀរ - មានពៀរវេរានឹងគ្នា - ពៀរតាំនៀរ... ។

បងខ្ញុំបានប្រទះនឹងស្រីម្នាក់ខ្វាក់ភ្នែកទាំងពីរ ពកូនដើរសូមទានគេ

ដូចកាលដើរតាមលើបន្ទា ដូចណាប៉ះនឹងដង្គត់ឈើ បើគេដាក់ខាងអ៊ីទៀត គាត់លើកដៃសំពះដូចពាសសួស្តីសាធុការគេ សេចក្តីវេទនានេះមកពីមានចៀរវេកតាមមកផ្តល់ ពាំនៀរទាំងនោះមិនដែលសាបសូន្យទេ ។

## ពិ _ ពី _ ពីរ

ត្រូវចំណាំពាក្យពីរម៉ាត់ «ពិនិងពី» ដែលអ្នកសរសេរច្រើនច្រឡំជាញឹកញយ ហើយគិតស្មានថាឥតខុសទៀតផង ។ ពាក្យដែលមាន «ពី» នៅខាងមុខ នោះមានចំនួនតិចជាង «ពិ» នៅខាងមុខ ដូចមានខាងក្រោមនេះ ៖

ពិ = ពិការ, ពិគ្រោះ, ពិឃាដ, ពិនិត្យពិច័យ, ពិចារណា ពិចិត្រ, ពិជ័យ, ពិដោរក្ងិន, ពិតាន, ពិទូរ្យ, ពិន័យ, ពិបាក ពិពេជ, ពិសាខបូជា, ពិសេស, ពិសោធន៍ ។ ល ។

ពី= ន. ត. និ: ( អំពី – ខាង – ឯ ) មកពីណា, រូបពីដៃ, សំដីចេញពីមាត់, ពីមុខ, ពីក្រោយ , ពីព្រោះ, ពីកោះ, ពីសីឬពិសី ពីសាឬពិសា, ពាក្យដែលមាន «ពី» នៅពីមុខមានតែប៉ុណ្ណឹង

ពីរ= ( ចំនួនមួយនឹងមួយគួបគ្នាត្រូវជាពីរ ) ពីរ បី... ។

កាលពីថ្ងៃមុនខ្ញុំបានមកពីគ្រោះទឹកលោក សូមឲ្យលោកពិនិត្យរឿង
ស្រូវពិការ អំពីហេតុដែលគេពិន័យឥតមានពិភាក្សាឲ្យឃើញខុសត្រូវ
ក៖ ។

### ពេបន៍–ពេជ្រ–ពេជ្ឈ

ពេបន៍ = ន. (ពាក្យសំដី) ពាក្យពេបន៍ – អ្នកបេះពាក្យពេបន៍

ពេជ្រ = ត្បូងពេជ្រ – ចិញ្ចៀនពេជ្រ – ពេជ្រថ្ម...

ពេជ្ឈ = ពេជ្ឈឃាដឬឃាត (អ្នកពិឃាតមនុស្សទោស)... ។

អ្នកបំនញគួនម្នាក់រកស៊ីលក់ត្បូងពេជ្រគ្រប់យ៉ាង បេះពាក្យពេបន៍
ឲ្យបងស្តាប់ បាំរឿងព្រេងជាច្រើន គាត់និទានថា មានព្រះមហា
ក្សត្រិយ៍មួយព្រះអង្គទ្រង់ត្រាស់បង្គាប់ពេជ្ឈឃាតឲ្យយកមនុស្សក្បត់ម្នាក់
ទៅពិឃាតឥតមានជំនុំជំរះ ។

### ពត់–ពុត–ពុទ្ធ–ពុធ

ពត់ = ពត់ដម្រង់ ពត់ចិត្ត, ពត់ព្រួញ....

ពុត = ពុតត្បុត, មានពុត, ដេញពុត, សម្លាប់ពុត

ពុទ្ធ = ព្រះពុទ្ធរូប, ព្រះពុទ្ធ, ធម៌, សង្ឃ, ពុទ្ធដីកា

ពុធ = ថ្ងៃពុធ ផ្កាយពុធ... ។

ពីថ្ងៃពុធ មានកុមារម្នាក់ពុតធ្វើជាឈឺ គេចវេះមិនទៅសាលារៀន បង់តាមលោកទៅលេងផ្សារទិញស្បង់ចីពរនឹងព្រះពុទ្ធរូប កិរិយាក្មេងបែបនេះពិបាកពត់ដម្រង់ណាស់ ។

## ពស់-ពោះ-ពោធិ៍-ពោរ

ពស់ = ពស់វែក, ពស់ព្រលិត, ពស់ក្រាយ...

ពោះ = ឈឺពោះ, មានពោះពុង, ពោះម៉ាយ...

ពោធិ៍ = ដើមពោធិ៍, ពោធិព្រឹក្ស, ព្រះពោធិសត្វ, ខេត្តពោធិ៍សាត់

ពោរ = ពោរពេញ, ពុះពោរ, ពេនពុម្ពមានសៀវភៅពោរពាស

លោកបានហ្វាន់ពេនពុម្ពឈឺពោះ ពីព្រោះលោកពិសាក្រូចពោធិ៍សាត់ដែលគេលក់ពោរពាសនៅតាមផ្លូវ ផ្លូវនេះបានថ្នាំស្រារូបពស់វែកកេតពោះនោះគ្រាន់បើហើយ ។

## ព្រ័ត្រ - ព្រាត់

ព្រ័ត្រ= ព្រ័ត្រក្របី, វេញព្រ័ត្រ, អុំទូកកាត់ព្រ័ត្រ

ព្រាត់= ព្រាត់ប្រាសគ្នា, ព្រាត់មិត្រសំឡាញ់... ។

ក្នុងឱកាសចូលឆ្នាំខ្មែរមានល្បែងច្រើនយ៉ាង ខ្លះលេងឈូង ខ្លះទាញព្រ័ត្រ ខ្លះបរគោក្របីសេះ អ្នកណាមានទុក្ខទោសព្រាត់ប្រាសទិសយ៉ាងណាក៏បានល្ហែនឹងគេដែរ ។

## ព្រុស - ព្រូស - ព្រួស - ព្រោះ

ព្រុស= កិ. ឆ្កែព្រុស, ឆ្កែព្រុសមិនដែលខាំ ។

ព្រូស= ន. ដើមព្រូស, ព្រីងព្រូស ។ ព្រូស. ១. (សូរព្ទ ដោយដួល) ដួលព្រូស

ព្រួស= កិ. ព្រួសទឹក ស្តោះព្រួស ។

ព្រោះ= កិ. ព្រោះស្រូវ, ព្រោះថ្នាំ ។ ព្រោះ អា. និ. (ហេតុដៀត) ព្រោះឈឺ, ព្រោះខ្ជិល...

ឆ្កែតាព្រូសវាព្រុសឆ្មាមួយអង្គុយនៅប្រគាបដើមព្រូស ឆ្មាក៏យប្រ
ស្រែកព្រួសទឹកមាត់ព្រោះខ្លាចឆ្កែខាំ ។

---

## ពាក្យទំនឹមទំនៀមបុរាណ

- ស្លូតស្លាប់ វៀចវេរមានភ័ព្វ អាយុយឺនយូរ
- រស់ក៏គាប់ឆាប់ក៏គួរ
- ក្របីស្នែងកែក មនុស្សស្រលៀនភ្នែក ក្រពើកំបុតកន្ទុយ
- អន្ទង់វែង រកឆ្នាំងវែង
- បង់ហោយឲ្យមើលប្រាណ ដាំដើងក្រានឲ្យប្រមាណឆ្នាំង
- ទំពក់វាទៅ ទើបពន្លាវាមក
- លួចគេវាធ្លាប់ដៃ ដេកថ្ងៃវាធ្លាប់ភ្នែក
- ស្រឡាញ់កុំទៅញឹក បើពេកសឹមទៅម្ដង ៗ
- កាលឈឺយកដំរីទៅបន់ លុះជម្ងឺស្រន់ពងមាន់មួយស្ដាយ
- មានសំពម ទើបឆ្កែវាជុះ
- ឆ្កែព្រុសមិនដែលខាំ
- ដំបៅមិនឈឺ យកឈើចាក់
- ម្នៅ ៗ យកដ័រពន្លោមកត្បៀតក្លៀក

– សូវស្លាប់បាឲ្យគង់មេ សូវលិចទូកកណ្ដាលទន្លេ កុំឲ្យតែភ្លើងឆេះផ្ទះ

– ទៅឥតគេរក មកឥតគេហៅ

– ទឹកត្រជាក់ត្រីកុម

– កំភ្លាញស្លាប់ពីព្រោះមាត់

– អឹមគៀមស្ងៀមជាជាងស្រដី ស៊ីបេកខ្ញីជាជាងនៅមាត់ទទេ

– កុំទុកចិត្តមេឃ កុំទុកចិត្តផ្កាយ កុំទុកចិត្តស្រីថាគ្មានសហាយ
កុំទុកចិត្តម្ដាយថាគ្មានបំណុល

– ទាហានស្បែកដាច ខ្លាចស្បែកស្វិត

## ភក្តិ–ភក្ត្រ–ភប់–ភព–ភ្លក្ស–ភ្លុក

ភក្តិ ឬ ភក្តី= ញាតិភក្តិ–មិត្តភក្តិ–ស្វាមីភក្តិ–ជំទប់ភក្តី

ភក្ត្រ ឬ ភ័ក្ត្រ= ព្រះភ័ក្ត្រ–ស្រពព្រះភក្ត្រ (លុបលាងមុខ)...

ភប់= កិ. ជួប–ប្រទះ–ភប់ប្រសព្វ ។

ភព= (ម.ថ.ភប់) សេចក្ដីចំរើន–ដំណើរកើត–ពិភពលោក ។

ភ្លក្ស ឬ ភ្លក់= ភ្លក្សសម្ល–ភ្លក់ឲ្យដឹងសាបប្រៃ . . . .

ភ្លុក= ភ្លុកដំរី–បូជាសពមានភ្លុក ៤ នាក់–ភ្លុកខ្មោច . . . . ។

ក្នុងកុដិលោកគ្រូហៅអធិការមានក្ដុកដំរីមួយគូ ដំកល់នៅចំព្រះភក្ត្រព្រះមានលោកពិភក្តិគ្រប់យប់ថ្ងៃដោយថ្នាក់ថ្នម ។ ក្នុងពិភពលោកនេះត្រូវគប់ប្រសព្វនឹងអ្នកប្រាជ្ញទើបមានភ័ព្វល្អ ។

## ព្យ នឹង ភ្ជ

ចូរចំណាំអក្សរពីរតួ " ព្យ និង ភ្ជ " ដែលគេច្រើនច្រឡំរបៀបជើង ជើង ជ នឹង យ ។

ជើងជត្រូវនៅក្រោមភ—ភ្ជ ។

ជើងយត្រូវនៅក្រោមព-ព្យ ។

ភ្ជ= ភ្ជ័រភ្ជាប់ភ្ជិត-ភ្ជើញសំពត់-ភ្ជុំភ្ជរ-ភ្ជួរស្រែចំការ-ជញ្ជាំងភ្ជុល

ព្យ= ព្យាយាម - ព្យាបាទ - ព្យាបាល - មួយព្យាម - ខ្យល់ព្យុះ - ព្យួរទោសបីខែ.... ។

លុះដល់ខែភ្ជុំបិណ្ឌ អ្នកស្រុកទៅភ្ជុំគ្នានៅវត្ត ដាក់បិណ្ឌរាល់ព្រឹក ខ្លះព្យាយាមណាស់នៅសំណាក់ក្នុងវត្ត មានបង្កៀនអុជព្យួរភ្លឺព្រោងព្រាត វេលាយប់ ។

## ម៉ដ្ឋ ឬ ម៉ដ្ឋ ម៉ត់ ឬ ហ្មត់

ម៉ដ្ឋ ឬ ម៉ដ្ឋ = (ម.ថ.ម៉ត់) (ដែលមានសាច់ល្អិត-ស្អិតជិត)

. សំពត់សាច់ម៉ដ្ឋ - មៀមម៉ដ្ឋខៃ...

ម៉ត់ ឬ ហ្មត់ = (អស់លើង- មិនមាន- មិនសល់) -ស៊ីហ្មត់-

ពោរលួចហ្មត់...

ហ្មត់ចត់= (ស្អាត – បរិសុទ្ធ) – ចិត្តហ្មត់ចត់ – ធ្វើការហ្មត់ចត់

(កុំសរសេរ ម៉ត់ចត់-ម៉ត់ម៉ង យ៉ាងនេះពុំសូវប្រើ) ។

ចិនមៅទៅផ្សារដើររកទិញសំពត់សាច់ម៉ដ្ឋល្អ គាត់រើសហ្មត់ចត់ណាស់បានប្រាំគី លុះយកទៅផ្ទះមានអាពោរលួចហ្មត់កងយប់នោះទៅ ។

## មាឌ ឬ មាត្រ - ម៉្រក្សណ៍ - ម្រាក់

មាឌ ឬ មាត្រ= ម.ថ. មាត (រាស់ – ថ្វីង – រូបរាង – ទម្ងន់ទំហំ) -មាឌធូក-មាត្រកញ៉ាល់-មាត្រប៉ុនគ្នា,

ម្រ័ក្សណ៍= ម.ថ. ម្រាក់-ន. លាបម្រ័ក្សណ៍ ម្រ័ក្សណ៍ខ្មៅ-

ម្រាក់= ន. (ក្មេងស្រីទើងស្រី) –ក្មេងទើងម្រាក់... ។

ក្មេងទើងម្រាក់មាឌប៉ុនគ្នា ប៉ុន្តែ ក្មេងប្រុសជាតិជាក្និគ្គ បានជាគាត់ខ្លា
រលោងដូចម្រ័ក្សណ៍ ។

យ៉ង់-យ៉ន្ត-យ័ន្ត

យ៉ង់= យប់យន់-យន់ត្របកភ្នែក-យន់កម្មាំង...

យន្ត ឬ យន្ត្រ= ម.ថ.យន់ – យន្តដែរ – យន្តហោះ–រថយន្ត ...

យ័ន្ត ឬ យ័ន្ត្រ= ម.ថ.យ័ន – គូរយ័ន្ត –បញ្ចុះយ័ន្ត–យ័ន្តការពារ
សត្រូវ...

យប់យន់ណាស់ទៅហើយ គេឮសូរយន្តហោះហើរលើអាកាស
ខ្លះកិតភ័យទាញយកពិតានដែលមានយ័ន្ត មកទទូរគ្របក្បាលការពារ
សត្រូវ ។

យា-យារ-យុត្តិ-យុទ្ធ

យា= យាយី-បីសាចមកយាយី (បៀតបៀន)...

យារ= ក្បួនយារ - សង្រែកយារ...

យុត្តិ ឬ យុត្ត= ត្រឹមត្រូវ - យុត្តិធម៌ (សេចក្តីត្រឹមត្រូវ, ទៀងត្រង់) យុត្តការណ៍ (ហេតុដំណើរដ៏គួរ) យុត្តកិច្ច (កិច្ចត្រឹមត្រូវ)....

យុទ្ធ= ចម្បាំង, សង្គ្រាម, តយុទ្ធនឹងគ្នា... ។

ប្រពន្ធបុរសនោះមិនមែនជាស្រីមាយាទេ គ្នាឈឺយូរយារណាស់មក ហើយ ត្រូវតាយថាខ្មោចខាងម្តាយមកយាយី ឥឡូវប្តីចង់ប្តឹងលែង ប៉ុន្តែ ចៅក្រមវិនិច្ឆ័យក្តីនេះដោយយុត្តិធម៌ កាត់សេចក្តីថាត្រូវជានឹងគ្នាវិញ ។

## រត់ - រថ - រុត

រត់= រត់លឿន - រត់បោលស្រុក រត់ពួន - រត់ទព...

រថ= រទេះរថ រថសេះពីរ - ជិះរថទៅលេងកំសាន្ត

រុត= រុតត្រី-យកអង្រុតទៅរុតត្រី... ។

ពីដើមមានរថសេះមួយឬសេះពីរជាច្រើន ឥឡូវនេះគេប្រើរទេះឡានវិញ រត់លឿនជាងរថទាំងអស់ ។ អ្នកស្រែរុតត្រីនឹងអង្រុត បើត្រីបោលក្នុងទឹក គេស្ទុះលោតរត់តាមស្ទាក់ពីមុខពីក្រោយទាល់តែរុតបាន ។

## រន្ធ – រុន – រស – រស់

រន្ធ=(ម.ថ.រន់) – រូង – រន្ធកណ្ដុរ – រន្ធចង្រិត

រុន=ពួកកក់ – ដើមរុន – កន្ទុលរុន

រស=(ម.ថ.រស់) – សម្ពស្សប្លែក ៗ ដែលប៉ះពាល់ជិវ្ហាបសាទ ឲ្យដឹង ប្រៃ, ជូរ, ចត់, អាហារមានរសឆ្ងាញ់

រស់=មានជីវិតនៅ – រស់នៅ បានរស់រានមានជីវិតតទៅ ។

ចៅរស់ឃើញរន្ធក្ដាមនៅក្បែរគុម្ពរុន ក៏លូកដៃចាប់បានក្ដាមមួយ យកទៅដុត អាស្រ័យទាំងរស់មានរសជាតិក្រៃលែង ។

## រាក – រាគ – រាង – រៀង

រាក=(គឺលេចដោយពន់ខ្លាំងទប់មិនទាន់) – ក្អួតរាកទោម រាកអាចម៍ – បុះរាក – រាករូស មាន់រាកស៊ុត...

រាគ=ម.ថ.រាគ: (គឺតម្រេកត្រេកត្រអាលចំពោះកាម) ចិត្តប្រកប ដោយរាគ:...

រាង=រាងចាល – រាងលែងធ្វើទៀតហើយ – រូបរាង – រាងស្ដើង....

រៀង= ឈររៀងគ្នា រៀងរាប រៀងរាយ លេខរៀង... ។
រូបរាងគាត់ស្គាំងស្គមរៀងរាបដរាបមក ដោយរាគៈគ្របសង្កត់ ហើយនឹងរោគរាកជានិច្ចទៀតផង ។

**រង់ - រង្គ - រុង**

រង់= ការរង់ រង់ចាំបន្តិចសិន...

រង្គ= ម.ថ. រង់ (គ្រឿងជ្រលក់ពណ៌លឿង) - ជ័ររង្គ ...

រុង= រុងរឿង - ថ្កុំថ្កើង (កុំសរសេរយ៉ាងនេះ រង់រឿង) ថ្កុំថ្កើងឬ ថ្កុំថ្កើង ប្រើបានដូចគ្នា ។

បើជាងគំនូរមកដល់ ឲ្យគាត់រង់ចាំខ្ញុំសិន ខ្ញុំនឹងទៅជាមួយបង្ហាញផ្ទះ ដែលមានរង្គលក់ច្រើន រើសយកតែពណ៌ស្រស់ល្អរុងរឿង ។

**រាជ - រាជ្យ**

រាជ= (សរសេរឥតជើង «យ») រាជសម្បត្តិ គឺសម្បត្តិ របស់ព្រះរាជាសំរាប់ព្រះអង្គ ដូចជា រាជទ្រព្យ-រាជនារី- រាជបុត្រ-រាជទូត-រាជប្រកាស...

រាជ្យ = សរសេរមានជើង "យ" រាជ្យសម្បត្តិ គឺសម្បត្តិ

សំរាប់រាជ្យឬសំរាប់ផែនដី ពុំមែនសំរាប់ព្រះរាជាទេ ដូចជាព្រះខ័នរាជ្យ - មកុដរាជ្យ - បល្ល័ង្ករាជ្យ - សោយរាជ្យ - ប្រទេសឯករាជ្យ

ព្រះខ័នរាជ្យគេដំកល់ទុកក្នុងព្រះបរមរាជវាំងគឺជាទ្រព្យសំរាប់រាជ្យ ។

«ការចំណាំ៖ បើពាក្យ (រាជ) នៅចុងពាក្យត្រូវសរសេរ រាជ ជើង - យ (រាជ្យ) ដូចជាព្រះខ័នរាជ្យ, មកុដរាជ្យ»

## រាន - រៀន - រាប - រៀប

រាន = រានហាល - រានមាន់ - លក់រាន - រានស្រែចំការ

រានភូមិ - មនុស្សរានចំណី - រុករានទន្ទ្រាន...

រៀន = រៀនធ្វើការ - រៀនសូត្រ - រៀនចំណេះវិជ្ជា

រាប = ដីរាប - គោរាប - ឫកពារាបទាប - រាបស្មើ - រាបសា

រៀប = ទៀប - ហៀប - រៀបស្លាប់ - រៀបនឹងលាគ្នា - រៀបចំ

រៀបខ្លួនប្រាណ...។

សិស្សម្នាក់ឫកពារាបទាប អង្គុយទន្ទេញមេរៀន នៅរានហាលមុខផ្ទះ ដ៏មានផើងផ្ការៀបដាក់ជាជួរ ។

## ភារ - រៀវ

ភារ= ការចាប់ត្រី ការរកឲ្យឃើញ - ខ្វាញ់ការ - ឋបនការ - ការបាន ។

រៀវ= កងរៀវ, រំពាត់រៀវ, តួបរៀវ

មានតាចោរម្នាក់កងរៀវខ្ពស់ ចូលទៅអែបក្បែរផ្ទះបាយគេហើយលូកដៃតាមបន្ទោះជញ្ជាំងការរករបស់ទ្រព្យ ក៏ប្រទះបានបានមួយភារយ៉ាងថ្មី ។

## លក្ខ - លក្ខណ៍ ល័ក្ខ - លាក់

លក្ខ ឬ លក្ស=ម.ថ.ប័គ ន. កំរិត សេចក្ដីកំណត់ ទីមានលក្ខខណ្ឌ - សំដីមានលក្សខណ្ឌ ។

លក្ខណ៍ ឬ លក្សណ៍= ន. ស្រីមានលក្ខណ៍ - ខាតលក្ខណ៍ - លក្ខណៈបរិបូណ៌

ល័ក្ខ ឬ ល័ខ= ន. ល័ខដុំគន្ធ៍ - ល័ខខៀវ - ល័ខខ្មៅ

លាក់=កិ. លាក់របស់, លាក់ពុត, កាប់លាក់ឈើ... ។

មនុស្សនេះខាតលក្ខណ៍ កាត់សក់លាក់ជើងកញ្ជើ និយាយប៉ប៉ាច់ប៉ប៉ោចឥតមានលក្ខខណ្ឌ ហើយស្លៀកខោជ្រលក់ល័ខបៃតងខុសពីគេទៀតផង ។

| លក់ - លុក - លង់ - លុង |
|---|

លក់=លក់ទំនិញ - លក់ថ្លៃ - ដេកលក់ - លក់លន់

លុក=លុកលុយ - លុកទ័ព - លុកព្រៃ - ចូលលុកក្នុងផ្ទះ

លង់=ជ្រុលហួសស៊ុន - លង់គំនិត - លង់ទឹក - យូរលង់

លុង=ជីកជាប់ជាំរលុង - រូង - រូងលុងដី - លុងឈើ - ជីកលុង ។

មេឃុំពិន័យលក់ម្ចាស់សេះដែលធ្វេសប្រហែស លែងសត្វពាហនៈនេះឲ្យលុកលុយស៊ីដំណាំគេ ប៉ុន្តែម្ចាស់អង្វរថា ខ្ញុំបាទបានជាលង់គំនិត គិតតែលុងឈើធ្វើទូកចម្លងគេយកបុណ្យ ។

| រលា - លលា - លលាដ៍ |
|---|

រលា=កិ. ឬ គុ. (រសាយរមូរ រសាយចំណង) ខ្សែរលា

រមុំអំបោះរលា....

លលា=(ម.ថ. លៈលា) គុ. លលាទឹកមាត់, (ធ្លុតទឹកមាត់, ពក់-ពាក់) តាលលាតែ (និយាយក្លាយជាលេលាក៏មាន)

លលាដ៍= (ម.ថ.លៈលា ) ន. (ឆ្អឹងក្បាល) លលាដ៍ក្បាល លលាដ៍ដូង ។

តាលលាតែម្នាក់ កាន់លលាដ៍ដូងនៅដៃ ដើរទៅឈរក្បែរស្រីម្នាក់កំពុងតញ្ញាញសំពត់ ហើយយកលលាដ៍ដូងបោលទៅលើក្ដារម្សៅជាប់រលាត់ពោះអស់ ។

| ល់ប - លុប - លស់ - លួស - លោះ |
| --- |

លប់= ន. លប់លលក. លប់ទធា, ក្រួចជាប់លប់...

លុប= កិ. លុបអក្សរ, លុបមុខ, លុបលាង, សំដីលុបលើ.....

លស់=កិ. គ្រុនលស់, ដើរលស់ជំហាន, លស់លាត្រាប្រណី

លួស=កិ. ន. លួសមែកឈើ, លួសអំពៅ លួសសំណរលួសបាយ, រលួសផ្ទុង...

លោះ=កិ. លោះរបស់បញ្ចាំ លោះកែកាំភ្លើង – លោះស្នា ។

ព្រានព្រៃក្រោកពីព្រលឹមលុបមុខយ៉ាងរហ័ស រួចទាញយកលប់

ទៅដាក់លលកព្រាប គាត់យកលួសចងលប់ភ្ជាប់នឹងកូនរលួសមួយដើ
តូប ព្រាននេះចិត្តអាក្រក់ណាស់ឥតមានលស់លាត្រាប្រណីអ្នកណា
ឡើយ អំពើអាក្រក់នេះហើយ បានជាព្រានក្រលំបាកលក់កូនឲ្យនៅ
គេរកប្រាក់លោះកូនពុំបាន ។

**លាង - លៀង - លាប - លាភ - លៀប**

លាង = កិ. លាងដៃ - លាងចិត្ត - លាងបាប - លាងពៀរ

លៀង = កិ. លៀងជីវិត, លៀងភ្ញៀវ, ស៊ីលៀង, លៀងលោម លៀងអារក្ស

លាប = កិ. លាបប្រេងម្សៅ - យកឈ្មោះគេមកលាប

លាភ = ន. មានលាភ - កើតលាភ

លៀប = ន. ឈើពួកជ្រៃ ដើមលៀប ត្រួយលៀបប្រើជាអន្លក់ ។

មានមួយយប់នោះគេបានអញ្ជើញមន្ត្រីម្នាក់នឹងភរិយាទៅជប់លៀង ប្ដីនឹងប្រពន្ធក៏មុជទឹកដុសលាងខ្លួនប្រាណ រួចស្លៀកពាក់សិតសក់លាបប្រេងម្សៅផូរផង់ គិតថាយប់នេះលាភយើងដល់ហើយ ។

## លាន - លៀន - លិប - លេប

លាន= ន. លានបោកស្រូវ, លានចេតិយ, មុខព្រះលាន

លៀន= កិ. លៀនអណ្ដាត - ក្អែកលៀនត្មៃ.....

លិប=កិ.ន. លិបចុះបាត់ទៅ - ទូកលិប - ព្រះអាទិត្យលិប -

លិបកញ្ជង់លង់កញ្ជើ - ទិសខាងលិប (ឡិប)

លេប=ចេញពីកំបាំង - កិ. លេបសំដី - លេបដំណឹង - លេបវាល

ចូលព្រៃ - គុ. ក្អមលេប - ផ្ទះលេប - ន. កើតដំបៅលេប ៗ

ចៅលឹមកើតដំបៅលេបលៀនត្មៃ ដើរទៅឆ្ងាយពុំបាន អង្គុយ

នៅលានស្រូវឪពុកវា ទាល់តែថ្ងៃលិចទើបជិះក្របីទៅផ្ទះ ៗ

## វដ្ដ - វត្ត - វត្ស៍ - វ័ធ - វាត់

វដ្ដ= ម.ថ. វត្តៈ ដែលវិល - ដំណើរវិលកើតស្លាប់ - វដ្ដសង្សារ

(ដំណើរវិលកើតស្លាប់) វដ្ដទុក្ខ

វត្ត= វត្តលោក - សាលាវត្ត - វត្តបដិបត្តិ

វិត្ស៍ ឬ វិត្ស =បៀវត្សរ៍ (ប្រាក់ខែឬប្រាក់ឆ្នាំ) សតវត្ស

(ឆ្នាំមួយរយឬមួយខួបរយឆ្នាំ...)

វិធ =ក្របីវិធគោផ្កាយពោះស្លាប់.... ។

វាត់=វាត់សន្ទូច-វាយវាត់ទឹងរំពាត់ ។

បើអ្នកបានធ្វើនាម៉ឺនមានបៀវត្ស ត្រូវតែអ្នកទៅវត្តប្រឹងធ្វើបុណ្យទាន ដើម្បីចាកលះបង់វដ្តសង្សារ កុំធ្វើបាបគេ ជេរពោលវាយវាត់ ដោយអំណាចនៃបុណ្យសក្តិ៍ ក្រែងមានពៀរដូចមន្ត្រីខ្លះស្លាប់វេទនាទឹងលង់ទឹក និងក្របីវិធក៏មានដែរ ។

| វា - វារ - វៀរ - វាង - វៀង |
| --- |

វា =កូនគោវាស្រែករកមេវា—វាវល់មកពុំបាន

វារ=កូនបេះវារ—ត្រឡាចវារទៅល្ពៅវារមក

វៀរ=វៀរចាកទុច្ចរិត-វៀរតែ-វៀរលែង

វាង= ផ្លូវវាង គំនិតវាង—សំដីវាងវៃ

វៀង =(រាជធានី-ក្រុង-វាំង)-វៀងចន្ទន៍ (ក្រុងចន្ទន៍) -វៀងជ័យ

(ក្រុងឬវាំងមានជ័យ)

កូនវាទើបតែនឹងចេះវារ ហើយវាជាមនុស្សមានប្រាជ្ញាវាងវៃណាស់ វាធ្វើជំនួញនៅវៀងចន្ទន៍ វាវៀរចាកទុច្ចរិតទាំងអស់ ពិតមែនតែវ័យនៅក្មេងនៅឡើយ ។

## វាត-វាទ-វិហា-វិហារ

វាត= កិ. វាតទី, វាតមុខ, វាតឆារ, វាតទូក ន. វាតរោគ (ជម្ងឺខ្យល់)

វាទ= ន. កើតវិវាទនឹងគ្នា (កើតហេតុនឹងគ្នា)

វិហា= ន. (អាកាស - ឋានសួគ៌) ហោះហើរលើវិហា (អាកាស)...

វិហារ= ន. (ការនៅ.អាស្រ័យ) សង់វិហារ បុណ្យឆ្លងវិហារ ។ ជាងវិហារ វាតអំណាចត្រួតត្រាលើជាងឯទៀត ឈ្មោះជេរគ្នា ឥឡូវកើតវិវាទនឹងគ្នា ដល់ទៅតុលាការជំនុំជំរះ ។

## ស-សរ

ស= គុ. សំពត់សក្បុស-សត្រសុស

ស= កិ. សត្រី - សរកឲ្យឃើញ សសេចក្តី - សហេតុ - សកេរ្តិ៍ សគល់ "ត្រកូលសជាតិ មារយាទសតូច"

សរ= ន. ព្រួញ, កាំ, ស្តេចផ្ទៃនសរ, កូនសរ, សរជ័យ

សរ= កិ. រំពឹកនឹកឃើញ, សរជាតិ, (ដីនជាតិ) សរញាណ ចិត្តសរសន់, សរសើរមារយាទ, សរសេរអក្សរ សរសៃសូត្រ, សសរផ្ទះ, ដើរសសៀរតាមជញ្ជាំង ។

អ្នកនេសាទត្រី យកស្នួយមានមុខស្រួចសដូចសំឡី ទៅសត្រី ក្នុងបឹង ។ យក្ខិនីត្រូវសរក្ស័យជីវិត ហើយសរជាតិថា កាលពីមុន ខ្លួនប្រព្រឹត្តអំពើអាក្រក់ បានពិឃាតសត្វជាច្រើន ។

## ស័ក - សក្តិ - សាក់

ស័ក= ន. កាល, សម័យ, ឯកស័ក, ទោស័ក, ឆ្នាំជូត សំរិទ្ធិស័ក, ឆ្លូវឯកស័ក, ខាលទោស័ក

សក្តិ ឬ ស័ក្តិ= ន. មានសក្តិ, ស័ក្តិតូច, សក្តិធំ, ថ្នាំស័ក្តិសិទ្ធិ (ពូកែឆុតឆាប់)

## សត្ត-សត្វ-សាត់

សត្តឬសត្វ= (ម.ជ. ស័ត) សត្តឃាត ឬ សត្វឃាត (ការសម្លាប់សត្វ) ផ្សារសត្តឃាត (ផ្សារពិឃាត) សាច់សត្វ-ព្រះពោធិសត្វ ... ។

សាត់= (ប៉ើន-ហើរតាមខ្យល់-អណ្តែតតាមទឹក) សាត់អណ្តែត, សាត់ព្រាត់, សំណាត់សាត់តាមខ្សែទឹក ... ។

នៅខេត្តពោធិ៍សាត់មានទីពិឃាតសត្វមួយ គេយកសាច់សត្វទាំងនោះទៅលក់ឯផ្សារឲ្យថណ្ណាជនក្នុងក្រុង ។

## សប់-សប្ន-សព-សព្វ

សប់= សប់ទឹក, សប់គន់, មនុស្សប្រសប់, បេះដប់ពុំស្មើនឹងប្រសប់មួយ...

សប្នឬសប្ត-សប្តិ= យល់សប្ន, យល់សប្តិ៍, យល់សុបិន...

សព= បូជាសព ដំកល់សព លើកសព...

សព្វ= សព្វគ្រប់, សព្វសាយ ប្រសព្វមុខ ទឹកហូរ ប្រសព្វគ្នា...

លោកគ្រូព្រះសព លោកប្រសប់ការងារគ្រប់សព្វទាំងអស់ ការណ៍ក្រយ៉ាងណាក្តី ក៏លោកដោះស្រាយបានស្រួលឥតទើសទាស់ឡើយ ពីយប់មិញខ្ញុំយល់សប្តិឃើញលោកនិមន្តមកវត្តវិញ ។

## សា – សារ

សា– ក. សាកន្ទួល, សាស្រូវ, សាមកវិញ ដើរសាចុះសាឡើង ។ ខ. ស្រូវសា, ផ្លឹកសា (ដែលដុះពីគល់ឡើងវិញ) សាត្រី (ក្ងា) ឈ្មោះបែកសា...

សារឬសារៈ= ខ្លឹមសារ, សរសេរសារផ្ញើទៅ (សំបុត្រ) ឥតសព្ទ ឥតសារ សារព្រឹក្ស (ឈើមានខ្លឹម) សារត្រា, ដំរីសារ, សារពាង្គកាយ, សារពើ សារពេជ្រ, សារកាព...

ដំរីសារស្លាប់យកចង្អេរបាំង លុះបាំងមិនជិតក៏ខឹងប្រឡោតឈ្មោះ ដេរគេជិតខាងបែកសាយាមោ ។

## សុក - សុក្រ - សុខ

សុក= ន. សុកកូន, ទឹកប់សុក, បងប្អូនប្រជាក់ទងសុក...

សុក្រ ឬ សុក្ក = ផ្កាយសុក្រ, ថ្ងៃសុក្រ...

សុខ =គុ. សុខសប្បាយ, សុខក្សេមក្សាន្ត, សុខសាន្ត, សុខទុក្ខ ។

កូនលោកកើតពីថ្ងៃសុក្រ អាចារ្យនឹងឪបង្គាប់ឲ្យយកសុកទៅកប់ខាងទិសនិរតី ដើម្បីឲ្យទារកនឹងមាតាបានសេចក្ដីសុខសប្បាយ អាយុយឺនយូរថែមទាំងឲ្យឈ្មោះហៅសុខទៀតផង ។

## សូ - សូរ - សូរ្យ

សូ= ន. (ខ្សែមាសឬប្រាក់មានសណ្ឋានជាប្រវ៉ាក់) ខ្សែសូ...

សូរ= (សព្ទសម្លេង) សូរគ្គរ, សូរសព្ទ, សូរសៀង...

សូរ្យ= ន. (ព្រះអាទិត្យ) សូរ្យសែង (ពន្លឺព្រះអាទិត្យ)

សូរ្យគ្រាស (ដំណើរដែលរាហូចាប់ឬបាំងព្រះអាទិត្យ) ។

កាលពីថ្ងៃអាទិត្យមុនមានសូរ្យគ្រាស គេបានវាយស្គរវាយជួងឮសូរ

ពងគ្រប់វត្ត ស្រីខ្លះពាក់គ្រឿងអលង្ការ មានទំហូនឹងខ្សែសូជាដើម អង្គុយថ្វាយបង្គំសូត្រគ្រាសនៅកនហាលមុខផ្ទះ ។

## សូន – សូន្យ

សូន = កិ. សូនរូបក្រមួន, សូនគុលិកា..... ។

សូន្យ = គុ. សូន្យសុង, សូន្យសោះ, លេខសូន្យ... ។

លោកមេឃុំ បាននិយាយនឹងជាងស្មិតពីខែមុន ឲ្យយកដីឥដ្ឋសូនធ្វើរូបហនុមានមួយ ឥឡូវនេះជាងនោះ ក៏បាត់សូន្យឈឹង ពុំមានដំណឹងអ្វីសោះ ។

## សួ – សួរ – សួគ៌

សួ = កិ. សួស្ដួ – សួស្ដានម្ចាស់ – សួព្រ័ត្រ....

សួរ = កិ. សួរនាំ – សួរដំណឹង – សួរមាត់សួរពាក្យ – សំនួរ...

សួគ៌ = ន. ទេវលោក – ឋានសួគ៌ – ផ្លូវសួគ៌... ។

លោកអាចារ្យសួរទៅទៅអ្នកជិតខាងថា ស្ដួដែលអ្នកពល់គ្នាសួ ទៅកាន់ឋានសួគ៌បាន តើទីពឹងលើផ្លូវណា ឆ្លើយថាទីពឹងផ្លូវធម៌ ។

## សំរាន្ត – សំរិត – សំរិទ្ធិ

សំរាន្ត = លោកសំរាន្ត ឬ លោកសម្រាន្ត – ជម្ងឺស្រាកស្រាន្ត
ជាសុខសាន្ត...

សំរិត = (ធ្វើឲ្យស្អាតឲ្យបរិសុទ្ធ) – សំរិតសំរាំង – អង្ករសម្រិត...

សំរិទ្ធិ = (សេចក្ដីសម្រេច – ចំរើន) សំរិទ្ធិជ័យ – ផលសំរិទ្ធិ... ។

ប៊ូលឯងសម្រាកបន្តិចចុះ លុះដល់ម៉ែគាត់ក្រោកពីសម្រាន្ត ឯងយកផលសំរិទ្ធិនេះដាក់អង្ករសំរិតឲ្យពេញទៅជូនគាត់កុំខាន ។

## ស្និត – ស្និទ្ធ – ស្នើ – ស្នើរ

ស្និត = ន.ស្និតបេក – ស្និតសិតបៃ – ស្និតស្នៃង...

ស្និទ្ធ = (ស្រឡាញ់អស់ពីចិត្ត) មនុស្សស្និទ្ធនឹងគ្នា – ស្និទ្ធស្នាល
ស្និទ្ធស្នេហ៍...

ស្នើ = (សួរឲ្យដឹងសិន) ស្នើការ – ទូលស្នើរ...

ស្មើរ= (ស្រទាប់សង្កត់) ហើយកតាមស្មើរ-មួយស្មើរ-(មួយពីរ សន្ទឹក)...

មានសិស្សពីរនាក់ស្ទុះស្ទាលទឹងគ្នាណាស់ ពីល្ងាចមិញនាំគ្នាទៅទិញស្ទិតសិតថៃ រួចទិញបេកនួនមួយ ស្ទិតទឹងមួជប់ស្មើរយកទៅស្មើការទឹងគេ ក្រែងបានសម្រេចដូចប្រាថ្នា ។

## ស្មា-ស្មារ-ស្វា-ស្មោះ

ស្មា= ន. ស្មាគាង-ស្មាក្តី-ស្មាគម.....

ស្មារ= ស្មារតីឬស្មារ្តី-មានស្មារតី-ស្មារលាទោស....

ស្វា= (កំណាញ់)-ស្វារជន-ចិត្តស្វារជន....

ស្មោះ= ស្មោះអារ (ខ្ជីខ្ជា)-ស្មោះសារ (សេចក្តីរកការ)-ស្មោះស្ម័គ្រ....

បុរសដែលមកពីថ្ងៃសុក្រ មុខភា ស្មាគាង ស្មារតីរង ចិត្តស្វារជន ឥតមានសេចក្តីស្មោះសរទឹងអ្នកដិតខាងឡើយ ។

## ស្រុស-ស្រុះ-ស្លេស្ម-ស្លេះ

ស្រុស= កិ. ស្រុសអន្ទក់ ស្រុសមាន់....

ស្រុះ= កិ.ស្រុះស្រួលគ្នា ស្រុះគ្នាដូចស្រមោច....

ស្លេស្ម= (ទឹករំអិលការចេញតាមបំពង់ក) ក្អកថ្លាក់ស្លេស្ម....

ស្លេះ= (ឈប់បង្អង់ទុក) ត្រូវស្លេះសេចក្ដីនេះទុកសិន... ។

ជីដូនចៅមាន គាត់ក្អកថ្លាក់ស្លេស្មមានឈាម កូនចៅគាត់ស្រុះគ្នាណាស់ ខ្លះរត់រកថ្នាំ ខ្លះរកស្លឹកឈើណាដែលត្រជាក់យកមកស្ងោរ ឬស្រុសយកទឹកឲ្យគាត់ពិសាឲ្យបានបាត់ក្អក ។

## ហត្ថ-ហាត់-ហា-ហារ

ហត្ថ= ន. (ដៃ) -ហត្ថលេខា-មួយហត្ថ-ហត្ថកម្ម....

ហាត់= កិ. ហាត់គុន - ហាត់រៀន - ហាត់ប្រាណ...

ហា= កិ. ហាមាត់ លៀសហាលថ្ងៃហា...

ហារ= ចែក-លេខហារ-ដើងហារ... ។

នៅសាលាហត្ថកម្ម មានហត្ថខាតគ្រប់យ៉ាងសំរាប់វាស់ មានកន្លែងហាត់ប្រាណ មានបន្ទប់រៀនសំរាប់សិក្សាខាងអក្សរ នឹងលេខ បូក សង គុណ ហារ ។

ហោ - ហោរ

ហោ= ឈើគុសមួយហោ ដេរប្រយ័ត្នកុំឲ្យហោ (ជ្រួញ)...

ហោរ= (ហោរា)-កូតនៅហោរ ហោរនៅជាង...

មានហោរម្នាក់នៅខាងលិចហោត្រៃវត្តយើង ល្បីឈ្មោះខាងទាយត្រូវណាស់ មនុស្សទៅមករកគាត់ហូរហែពុំសូវដាច់ទេ ។

ហ្វ - ហ្វត់

ហ្វ= ន. (ពេទ្យ) - ពេទ្យហ្វ - ហ្វមើលជម្ងឺ - ហ្វដំរី ហ្វថាវ

(ហ្វបាសុំ ជាគ្រូលើហ្វដំរីក្នុងពួកមួយ ៗ)

ហ្មត់= ( អស់ )-ភ្លើងឆេះហ្មត់, ហ្មត់ចត់ ( ត្រឹមត្រូវ )

ហ្មត់ហ្មង ( ឥតសៅហ្មងឬសុទ្ធសូន្យ ) ។

ហ្មថាវបញ្ញត្តទៅហ្មទាំងឡាយឲ្យខំធ្វើការដោយហ្មត់ចត់ កុំធ្វេសប្រហែសឲ្យសោះ បើមានហេតផ្សេង ៗ ត្រូវរត់រកពេទ្យហ្មយ៉ាងប្រញាប់ ។

## ពាក្យទំនឹមទំនៀមបុរាណ

- ចូលស្ទឹងតាមបត់
- អណ្ដាតជាអាទិ៍កន្លង អស់ទ្រព្យធនផងពីព្រោះអណ្ដាត
- ដឹងធ្វើយផ្សិតដង កូនចង្គងផ្សិតមេបា
- ឈើពុកកុំអង្គុយលើ
- អួសទូកកុំឲ្យលំអាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក
- ស្រឡាញ់ខ្លួនឲ្យស្ងួនចំណី ស្រឡាញ់ស្រីឲ្យស្ងួនចិត្ត
- ស្រឡាញ់មេរំពេដល់កូន
- ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំជា
- កាន់កពស់កាន់ឲ្យខ្ជាប់ ក្រែងក្រឡាប់ខាំឯប្រាណ

- ទឹកហូរមិនដែលហត់ មនុស្សស្បថកុំឲ្យជឿ
- ត្រីមួយត្រក ស្អុយតែមួយ ស្អុយទាំងអស់
- ពងមាន់កុំជល់នឹងថ្ម
- ធ្វូនទៅថ្មក្រទៅក្ដី
- ប្រាជ្ញពុំស្មើប្រប ចាក់ស្លឹកត្របៀកខូប ពុំស្មើល្មមល្មម
- គយដេកជាស់គយឲ្យអង្ករ
- កុំបំពត់ស្រឡៅ កុំប្រដៅមនុស្សខូច
- ទំពាំងស្នងឫស្សី
- ដំរីជុះកុំជុះតាមដំរី
- ដើរឲ្យមានបី ស្រដីឲ្យមានបួន
- សូវបង់ប្រាក់មួយថង់ កុំឲ្យបង់ពាក្យ
- ផ្ទះធំស្រណុក ព្រោះលក្ខណ៍ស្រីជា

## ហ្លួង – ល្ហួង

ហ្លួង = ន. (ព្រះកជា)= ហ្លួងយាង – ហ្លួងចបកជ ហ្លួងសេនានុរក្ស (ឈ្មោះតួបជាងព្រះ) ហ្លួងព្រះបាង... ។

ល្អឹ= កិ. លួងលោម លួងលួងឲ្យស្រួលចិត្ត... ។

ព្រឹកស្អែកនេះ ហ្វូងទ័ពយានចេញប្រពានរង្ហាន់ដល់ពួកក្រុមពិជ័យសង្គ្រាម ។ ហ្វូងស្ដេចចូលទៅក្នុងព្រះមហាដំណាក់ លួងលោមព្រះមហេសីមុននឹងចេញទៅក្រសាលឯព្រៃព្រឹក្ស ។

## អ_អរ_អំណរ_ល្អ_លំអ

អ= ន. បាយអ (កំបោរថ្មខ្លាប់លាយទឹក)–ផុំបុំអ (បុំបបុស)...

អរ= កិ. (មានអំណរ) អរគុណ–អរបានទ្រព្យ...

អំណរ= ន. (សេចក្ដីអរ) មានអំណរ...

ល្អ= គុ. ចិត្តល្អ–រូបល្អ–អំពើល្អ...

លំអ= ន. (សេចក្ដីល្អ)–លំអរូប...

ជាងយកកំបោរថ្មទឹងដីខ្លាប់លាយទឹកធ្វើជាបាយអ ហើយយកស៊ីម៉ង់ត៍លាយបញ្ចូលខ្លះទៀតឲ្យបានជាប់ល្អ ដើម្បីឲ្យម្ចាស់ផ្ទះត្រេកអរនឹងការរបស់ជាង ។

## អប្ប-អ័ព្ទ-អាប់

អប្ប= ម.ថ. អប្បៈ (តិច-ស្តួចស្តើង) អប្បទ្រព្យ-អប្បបញ្ញា

អប្បលាភ...

អ័ព្ទ ឬ អ័ព្ភ = (ពពកខាប់) - ចុះអ័ព្ទ-ងងឹតអ័ព្ទ-ធូលីហុយ

អ័ព្ទ អ័ព្ទអួ...

អាប់= (ដែលអន់ឬតិចពន្លឺ)-អាប់គំនិត-អាប់ជាតិ-អាប់

ប្រាជ្ញា (ខ្សោយ) -អាប់មុខ-អាប់រស្មី...

ព្រឹកមិញចុះអ័ព្ទពេញទន្លេ នាំឱ្យអ្នកអុំឬបែរទូកអាប់ប្រាជ្ញាទង ងងឹតអ័ព្ទនោះ រកផ្លូវស្ទើរតែពុំឃើញ ។

## អសារ-អាសន្ន-អាសា

អសារ= (ដែលឥតខ្លឹម-ប្រយោជន៍-ឥតអំពើ)-របស់

អសារឥតការ-សំដីអសារឥតការ...

អាសន្ន= (ជិត) -ភ័យអាសន្ន (ភ័យជិត) មានអាសន្ន-

ណ្ដោះអាសន្ន... ។

អាសា=ន. បំណង-សង្ឃឹមៈមានអាសា ។ អាសា-ប្រើជាៈ ន. ឬគុ. បានសេចក្ដីថា «ការជួយឈឺឆ្អាលដោយស្ម័គ្រចិត្តៈយកអាសាគេ»។

កាលពីខែដាច់ទៅ គាត់មានអាសន្ន បានតែមកខ្ចីប្រាក់ខ្ញុំមួយរយរៀល ខ្ញុំក៏យកអាសាគាត់ ដល់គ្រប់សន្យាហើយ ខ្ញុំទៅទារទ្វាចខូចប្រាក់អសារផុតការ គាត់ថាកុំកាលអាសន្នពេក អញមិនរត់ទៅណាទេ ។

## អាទិ_អត្ថ_អារ្យ

អាទិឬអាទ៏= ម.ឋ.អាត.ន. (ដើម-ដើមដំបូង) នាំអាទ៏

(នាំផ្ដើមមុន)-ធម្មតាអ្នកជាជាតិ កាលគេអាទ៏

ឲ្យគិតគូរ កុំខ្ជិលដេកទទូរ ដល់ថ្ងៃរះពេញពន្លឺ ។

អត្ថ= ម.ឋ.អ័ត-ន. (ប្រយោជន៍-សេចក្ដី-ពាក្យប្រែ

ស្រាយ-រឿងហេតុ) ស្គាល់អត្ថ (ស្គាល់សេចក្ដី)-

រៀនអត្ថ (រៀនសេចក្ដីអធិប្បាយ)...

អារ្យ= (អរិយ) (ប្រសើរ ត្រឹមត្រូវ-សុភាព)=អរិយធម៌ឬ-អារ្យធម៌ (ធម៌ដែលនាំឲ្យចំរើន សេចក្ដីសុខចំរើន)...

រៀនអត្ថហ្នត់ចត់ណាស់ បេះធមិអារ្យក៏ជ្រាជ្រះណាស់ដែរ
វតែនៅភ្ញាត់ម្តង ៗ ។

## បារម្ភ – អារម្មណ៍

បារម្ភ=(ការផ្តើម–សេចក្តីផ្តើម–ការនាំការ) ខ្ញុំមានបារម្ភខ្លាំង ទឹងការណ៍នោះអ្នកកុំបារម្ភឲ្យសោះ ខ្ញុំធានាជួយ ឲ្យខានតែបាន ។

អារម្មណ៍= (គ្រឿងគោងរបស់ចិត្ត–គំនិត–ការដឹង) អារម្មណ៍ មិនល្អមិនទៀង – ចាប់អារម្មណ៍ (ចាប់ចិត្ត អធ្យាស្រ័យ...) ។

អ្នកកុំបារម្ភទឹងការណ៍ដែលអ្នកពឹងខ្ញុំឲ្យជួយគិតគូរនោះ គេទឹងសម្រេចដូចចិត្តអ្នកប្រាថ្នា ប៉ុន្តែអ្នកកុំទាស់អារម្មណ៍ទឹងកិរិយារបស់អ្នក ត្រូវសន្តោសប្រោសប្រណីពីព្រោះគ្នាបានជាប្រព្រឹត្តហួសទៅហើយ ។

## អាច – អាចម៍

អាច=១. (ហ៊ាន – ធ្វើបាន – មិនរួញរា) – អាចធ្វើបាន – អាចជាបាន... ។

អាបម់= ម.ថ. អាប់ - (អាហារចាស់) - អាបម់ម -

អាបម់សត្វ...

អាបម់ល័ខអាបក្ល័រក្លាប់ភ្លឺផ្សេងៗបាន ដូចជាមៀនកាំបិត កណ្ដ ជាដើម មិនអាចនឹងរគ្គោះឆាយទេ ៗ

អា - អារ - រអា

អា= បុរិសសព្វនាម ជាពាក្យពាបឥតគួរសម - អាណា

អានេះ - អាឯង...

អា= គុ. ស្រីអា - មេគោអា (ឥតកូន)...

អារ= កិ. កាត់ - បំបែកៗ អាររំលំ - អាររំលំ - អារប្រៀក

រអា= កិ. ឬ គុ. - ពេញទ្រាន់ខ្លាំងៗ ចិត្តរអា - ខ្ញុំរអា-

ហើយ រអាសាច់ (ទ្រាន់សាច...) ។

អាពារនេះគេច្នៃទុកក្រោសព្វច្រើនលើកមកហើយ ក្នុងរអាសោ:

ឥឡូវនេះខ្ញុំមិនហ៊ានអារកាត់សេចក្ដីនេះទេ ។

រោងពុម្ពទវិយ

នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥

តម្លៃ ១៥៛